U.S. DEPARTMENT of STATE

TRAVEL.STATE.GOV BUREAU OF CONSULAR AFFAIRS

# សេចក្តីណែនាំសម្រាប់កម្មវិធីទិដ្ឋាការអន្តោប្រវេសន៍ (ឆ្នោត DV ឆ្នាំ ២០២០)

## ព័ត៌មានអំពីកម្មវិធីឆ្នោត

ក្រសួងការបរទេសសហរដ្ឋអាមេរិកត្រួតពិនិត្យកម្មវិធីឆ្នោត DV ដែលកំណត់ដោយសភាសហរដ្ឋអាមេរិក ជារៀងរាល់ឆ្នាំ។ មាត្រា ២០៣ (គ) នៃច្បាប់ស្តីពីអន្តោប្រវេសន៍និងសញ្ជាតិ (INA) ចែងអំពីប្រភេទនៃជនអន្តោប្រវេសន៍ដែលហៅថា "diversity immigrants" សម្រាប់ប្រទេសដែលមានប្រវត្តិអន្តោប្រវេសន៍ទៅសហរដ្ឋអាមេរិកមានកម្រិតទាប។ ទិដ្ឋាការឆ្នោត DV ចំនួន ៥០.០០០ ច្បាប់ នឹងត្រូវបានផ្តល់ជូនសម្រាប់ឆ្នាំ ២០២០។ គ្មានការបង់ប្រាក់ក្នុងការចុះឈ្មោះកម្មវិធីឆ្នោត DV ឡើយ។

បេក្ខជនដែលត្រូវបានជ្រើសរើសក្នុងកម្មវិធីឆ្នោត ("បេក្ខជនជាប់ឆ្នោត") ត្រូវមានលក្ខណៈដែលឆ្លើយតបទៅនឹងតម្រូវការដែលសាមញ្ញ ប៉ុន្តែតឹងរឹង ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទិដ្ឋាការឆ្នោត DV ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកជាអ្នកជ្រើសរើសបេក្ខជនជាប់ឆ្នោតតាមរយៈការចាប់ឆ្នោតដោយចៃដន្យ តាមប្រព័ន្ធកុំព្យូទ័រ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកបែងចែកទិដ្ឋាការឆ្នោត DV ទៅតាមតំបន់ចំនួនប្រាំមួយ ហើយមិនមានប្រទេសណាមួយដែលអាចទទួលបានច្រើនជាង ៧ ភាគរយ នៃចំនួនទិដ្ឋាការឆ្នោត DV ដែលមានក្នុងឆ្នាំណាមួយនោះឡើយ។

សម្រាប់ឆ្នោត DV ឆ្នាំ២០២០ ប្រជាជនដើមនៃបណ្តាប្រទេសខាងក្រោមនេះ មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីដាក់ពាក្យនោះទេ ដោយសារមានប្រជាជនដើមចំនួនច្រើនជាង ៥០.០០០ នាក់ មកពីប្រទេសទាំងនេះ បានធ្វើអន្តោប្រវេសន៍ទៅរស់នៅសហរដ្ឋអាមេរិកក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ៖

បង់ក្លាដេស ប្រេស៊ីល កាណាដា ចិន(ដីគោក) កូឡុំប៊ី សាធារណរដ្ឋដូមីនីក អែលសាល់វ៉ាឌ័រ ហៃទី ឥណ្ឌា ហ្សាម៉ាអ៊ីក ម៉ិកស៊ិក នីហ្សេរីយ៉ា ប៉ាគីស្ថាន ប៉េរូ ហ្វីលីពីន កូរ៉េខាងត្បូង ចក្រភពអង់គ្លេស(លើកលែងអៀរឡង់ខាងជើង)និងទឹកដីរណប និងវៀតណាម។

ប្រជាជនដែលមានទីកំណើតនៅ ហុងកុង SAR ម៉ាកាវ SAR និងតៃវ៉ាន់ នៅតែអាចដាក់ពាក្យបាន។

មិនមានការផ្លាស់ប្តូរលើលក្ខណៈសម្បត្តិសម្រាប់ឆ្នាំនេះឡើយ ប្រៀបធៀបនឹងឆ្នាំមុន។

**លក្ខណៈសម្បត្តិ**

**លក្ខខណ្ឌតម្រូវទី១៖** ជនដែលមានទីកំណើតនៅប្រទេសដែលប្រជាជនដើមមានសិទ្ធិដាក់ពាក្យអាចដាក់ពាក្យចុះឈ្មោះបាន។

ប្រសិនបើអ្នកមិនមានទីកំណើតនៅក្នុងប្រទេសទាំងនោះទេ អ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីដាក់ពាក្យបានតាមវិធីពីរផ្សេងទៀត ៖

- តើប្តី/ប្រពន្ធរបស់អ្នកមានទីកំណើតនៅក្នុងប្រទេសដែលប្រជាជនដើមមានសិទ្ធិដាក់ពាក្យដែរឬទេ? ប្រសិនមែន អ្នកអាចដាក់ពាក្យ តាមរយៈប្រទេសកំណើតរបស់ប្តី/ប្រពន្ធរបស់អ្នកបានតែក្នុងករណីដែលឈ្មោះអ្នកនិងប្តី/ប្រពន្ធរបស់អ្នកត្រូវបានបញ្ចូលទៅក្នុងបញ្ជីដែលបានជ្រើសរើស មានលក្ខណៈគ្រប់គ្រាន់ហើយត្រូវបានផ្តល់ទិដ្ឋាការ DV និងបានចូលទៅសហរដ្ឋអាមេរិកក្នុងពេលតែមួយ។
- តើអ្នកមានដើមកំណើតនៅប្រទេសដែលប្រជាជនដើមមិនមានសិទ្ធិដាក់ពាក្យមែនទេប៉ុន្តែឪពុកម្តាយរបស់អ្នកមិនមានដើមកំណើត ឬជាប្រជាជនរស់នៅស្របច្បាប់នៅក្នុងប្រទេសនោះនៅពេលដែលអ្នកកើតទេ? ប្រសិនមែន អ្នកអាចដាក់ពាក្យ តាមរយៈប្រទេសកំណើតរបស់ឪពុកឬម្តាយរបស់អ្នក ប្រសិនប្រទេសនេះជាប្រទេសដែលមានប្រជាជនដើមមានសិទ្ធិដាក់ពាក្យសម្រាប់កម្មវិធីឆ្នោត DV ឆ្នាំ ២០២០ សម្រាប់សេចក្តីលម្អិតស្តីពីព័ត៌មានខាងលើ សូមចូលមើលសំណួរដែលសួរញឹកញាប់បំផុត។

**លក្ខខណ្ឌតម្រូវទី២៖** បេក្ខជនឆ្នោត DV នីមួយៗត្រូវឆ្លើយតបនឹងលក្ខខណ្ឌកម្រិតសិក្សា/បទពិសោធន៍ការងារនៃកម្មវិធីឆ្នោត DV ដោយមានមួយក្នុងចំណោមខាងក្រោម៖

- យ៉ាងហោចណាស់បញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ ឬការសិក្សាមានតម្លៃស្មើ ដោយត្រូវបានកំណត់ថាបញ្ចប់ការសិក្សាដោយជោគជ័យរយៈពេល ១២ ឆ្នាំ នៃកម្រិតសិក្សាផ្លូវការនៅថ្នាក់បឋមសិក្សានិងមធ្យមសិក្សា។

**ឬ**

- បទពិសោធន៍ការងាររយៈពេលពីរឆ្នាំក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ ក្នុងការងារដែលតម្រូវឱ្យមានការបណ្តុះបណ្តាលឬបទពិសោធន៍យ៉ាងហោចណាស់ពីរឆ្នាំដើម្បីបំពេញការងារនោះ។ ក្រសួងការបរទេស

សហរដ្ឋអាមេរិកនឹងប្រើប្រាស់ប្រព័ន្ធទិន្នន័យ **O*Net Online** របស់ក្រសួងការងារសហរដ្ឋអាមេរិក ដើម្បីកំណត់អំពីលក្ខណៈសម្បត្តិបទពិសោធន៍ការងារ។

សម្រាប់ព័ត៌មានបន្ថែមអំពីលក្ខណៈសម្បត្តិបទពិសោធន៍ការងារ សូមចូលមើលសំណួរដែលសួរញឹកញាប់បំផុត។

មិនត្រូវចុះឈ្មោះកម្មវិធីឆ្នោត DV ឡើយ លើកលែងតែអ្នកបានបំពេញលក្ខខណ្ឌតម្រូវទាំងពីរខាងលើជាមុន។

## រដូវកាលនៃការចុះឈ្មោះ

បេក្ខជនត្រូវដាក់ពាក្យក្នុងកម្មវិធីឆ្នោត DV ឆ្នាំ២០២០ តាមប្រព័ន្ធអេឡិចត្រូនិចតាមគេហទំព័រ dvloterry.stage.gov ក្នុងចន្លោះថ្ងៃត្រង់នៃ Eastern Daylight Time (EDT) (GMT-4) ថ្ងៃពុធ ទី៣ ខែតុលា ឆ្នាំ២០១៨ និងថ្ងៃត្រង់នៃ Eastern Daylight Time (EDT) (GMT-5) ថ្ងៃអង្គារ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨។ សូមកុំរង់ចាំរហូតដល់សប្តាហ៍ចុងក្រោយនៃរដូវកាលចុះឈ្មោះ ដោយសារតែអាចមានការចុះឈ្មោះច្រើន ដែលអាចបណ្តាលឱ្យមានការពន្យារពេលនៅលើគេហទំព័រ។ ការចុះឈ្មោះឬការបញ្ចូលឯកសារមិនទាន់ពេលវេលា នឹងមិនត្រូវបានទទួលយកឡើយ។ ច្បាប់អនុញ្ញាតឱ្យមានការចុះឈ្មោះតែមួយប៉ុណ្ណោះសម្រាប់បេក្ខជនម្នាក់ក្នុងរយៈពេលចុះឈ្មោះនីមួយៗ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីស្វែងរកការចុះឈ្មោះច្រើនដង។ **ជនណាដែលចុះឈ្មោះច្រើនជាងមួយដងនឹងត្រូវអស់សិទ្ធិនៅក្នុងការចូលរួមកម្មវិធីឆ្នោត។**

## ការបំពេញពាក្យចុះឈ្មោះអេឡិចត្រូនិចសម្រាប់កម្មវិធីឆ្នោត DV ឆ្នាំ ២០២០

បញ្ចូលទម្រង់ ពាក្យសុំអេឡិចត្រូនិចរបស់អ្នកសម្រាប់កម្មវិធីឆ្នោត DV (E-DV Entry Form ឬ DS-5501)តាមរយៈគេហទំព័រ www.dvloterry.stage.gov ។ យើងនឹងមិនទទួលពាក្យចុះឈ្មោះដែលគ្មានព័ត៌មានពេញលេញឡើយ។ ការបញ្ចូលពាក្យចុះឈ្មោះនេះនឹងមិនមានគិតថ្លៃអ្វីឡើយ។ សូមធ្វើបច្ចុប្បន្នកម្ម (អាប់ដេត) កម្មវិធីផែកអ៊ីនធើណិត (browser) នៅពេលបញ្ចូលពាក្យចុះឈ្មោះរបស់អ្នក។ កម្មវិធីផែកអ៊ីនធើណិតស៊េរីចាស់ (ឧទាហរណ៍ Internet Explorer 8) អាចនឹងបង្កបញ្ហារអាក់រអួលជាមួយនឹងកម្មវិធីឆ្នោត DV តាមអ៊ីនធើណិត។

យើងសូមលើកទឹកចិត្តអ្នកក្នុងការបំពេញពាក្យចុះឈ្មោះនេះដោយខ្លួនឯង ដោយមិនចាំបាច់ត្រូវការ "អ្នកប្រឹក្សាទិដ្ឋាការ" "ភ្នាក់ងារទិដ្ឋាការ" ឬអ្នកសម្របសម្រួលផ្សេងទៀតដែលផ្តល់ជំនួយដល់អ្នកនោះឡើយ។ ប្រសិនមានបុគ្គលណាជួយអ្នក អ្នកគួរតែមានវត្តមាននៅពេលរៀបចំបញ្ចូលព័ត៌មាន ដូចនេះអ្នកអាចផ្តល់ព័ត៌មានដែលត្រឹមត្រូវទៅនឹងសំណួរនានា ហើយអាចរក្សាទំព័របញ្ជាក់ (confirmation page) របស់អ្នកនិងលេខពិសេសនៃទំព័របញ្ជាក់របស់អ្នកផងដែរ។ អ្នកត្រូវរក្សាទំព័របញ្ជាក់និងលេខពិសេសនៃទំព័របញ្ជាក់របស់អ្នក។ ប្រសិនគ្មាន

ព័ត៌មានទាំងនេះទេ អ្នកនឹងមិនអាចចូលទៅក្នុងប្រព័ន្ធអ៊ីនធើណិតដែលនឹងផ្តល់ព័ត៌មានជូនអ្នកស្តីពីស្ថានភាពនៃពាក្យចុះឈ្មោះរបស់អ្នកបានឡើយ។ សូមប្រុងប្រយ័ត្ននៅពេលមានបុគ្គលណាម្នាក់សុំជួយរក្សាព័ត៌មាននេះជូនអ្នក។ អ្នកក៏គួររក្សាគណនីអ៊ីម៉ែលដែលបានបញ្ចូលនៅក្នុងពាក្យចុះឈ្មោះ E-DV ផងដែរ។ សូមមើល សំណួរដែលសួរញឹកញាប់បំផុត សម្រាប់ព័ត៌មានបន្ថែមស្តីពីការឆបោកក្នុងកម្មវិធីឆ្នោត DV ។ អ្នកក៏អាចចូលទៅមើលវិឌីអូរបស់យើងស្តីពីការណែនាំកម្មវិធីឆ្នោត DV និងការណែនាំជាជំហានៗដើម្បីសម្រួលអ្នកក្នុងការដាក់ពាក្យ។

បន្ទាប់ពីអ្នកបានបញ្ចូលពាក្យចុះឈ្មោះពេញលេញហើយ អ្នកនឹងឃើញអេក្រង់បញ្ជាក់មួយ ដែលមានឈ្មោះនិងលេខកូតបញ្ជាក់ពិសេសរបស់អ្នក។ សូមព្រីនអេក្រង់បញ្ជាក់នេះសម្រាប់ទុកជាព័ត៌មានរបស់អ្នក។ ចាប់ពីថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៩ អ្នកនឹងអាចពិនិត្យមើលស្ថានភាពនៃពាក្យចុះឈ្មោះរបស់អ្នកតាមរយៈ dvloterry.stage.gov សូមចុចទៅលើការឆែកលទ្ធផលបេក្ខជន (*Entrant Status Check*) ហើយបញ្ចូលលេខកូតបញ្ជាក់ពិសេស និងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកថាតើអ្នកត្រូវបានជ្រើសរើសសម្រាប់ឆ្នោត DV ឆ្នាំ ២០២០ និងដើម្បីពិនិត្យមើលកាលបរិច្ឆេទថ្ងៃសម្ភាសន៍ទិដ្ឋាការអន្តោប្រវេសន៍របស់អ្នក ប្រសិនអ្នកត្រូវបានជ្រើសរើស។ រដ្ឋាភិបាលអាមេរិកនឹងមិនជូនដំណឹងដល់អ្នកដោយផ្ទាល់ឡើយ។ *Entrant Status Check* គឺជាប្រភពព័ត៌មានតែមួយគត់សម្រាប់ការណែនាំស្តីពីការបន្តដំណើរការពាក្យសុំរបស់អ្នក។ សូមពិនិត្យមើល សំណួរដែលសួរញឹកញាប់បំផុតសម្រាប់ព័ត៌មានបន្ថែមស្តីពីដំណើរការជ្រើសរើស។

អ្នកត្រូវតែផ្តល់ព័ត៌មានខាងក្រោមដើម្បីបំពេញពាក្យចុះឈ្មោះរបស់អ្នក៖

១. ឈ្មោះ៖ នាមត្រកូល នាមខ្លួន ឈ្មោះកណ្តាល ដូចឈ្មោះក្នុងលិខិតឆ្លងដែនរបស់អ្នក។ ប្រសិនអ្នកមានឈ្មោះតែមួយ អ្នកត្រូវបញ្ចូលនៅក្នុងប្រអប់នាមត្រកូល/នាមខ្លួន។

២. ភេទ៖ ប្រុស ឬ ស្រី

៣. ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃ ខែ ឆ្នាំ

៤. ទីក្រុងដែលអ្នកកើត

៥. ប្រទេសដែលអ្នកកើត៖ ដោយដាក់ឈ្មោះនៃប្រទេសដែលកំពុងប្រើប្រាស់បច្ចុប្បន្នសម្រាប់ទីកន្លែងដែលអ្នកកើត

៦. ប្រទេសដែលមានសិទ្ធិដាក់ពាក្យសម្រាប់កម្មវិធីឆ្នោត DV ។ ប្រទេសដែលមានសិទ្ធិដាក់ពាក្យរបស់អ្នកជាទូទៅ ដូចគ្នាទៅនឹងប្រទេសកំណើតរបស់អ្នកដែរ។ ប្រទេសដែលមានសិទ្ធិដាក់ពាក្យរបស់អ្នកមិនពាក់ព័ន្ធទៅ

នឹងទីកន្លែងដែលអ្នកស្នាក់នៅ ឬសញ្ជាតិរបស់អ្នកឡើយ ប្រសិនវាខុសពីប្រទេសកំណើតរបស់អ្នក។ ប្រសិនបើអ្នកកើតក្នុងប្រទេសដែលគ្មានសិទ្ធិដាក់ពាក្យទេនោះ សូមចូលទៅ សំណួរដែលសួរញឹកញាប់បំផុត ដើម្បីពិនិត្យមើលថាតើមានវិធីណាផ្សេងទៀតដែលអាចធ្វើឱ្យអ្នកមានសិទ្ធិដាក់ពាក្យ។

៧. រូបថតបេក្ខជន៖ ត្រូវតែជារូបថតថ្មី (ថតក្នុងរយៈពេលប្រាំមួយខែចុងក្រោយ) របស់អ្នក ប្តី/ប្រពន្ធអ្នក និងកូនៗអ្នកទាំងអស់។ សូមមើល បញ្ចូលរូបថតឌីជីថល សម្រាប់លក្ខខណ្ឌតិនភាគនិងបច្ចេកទេស។ អ្នកមិនចាំបាច់បញ្ចូលរូបថតសម្រាប់ប្តី/ប្រពន្ធឬកូន ដែលជាជនជាតិអាមេរិក ឬអ្នកមានសិទ្ធិរស់នៅស្របច្បាប់នៅអាមេរិកនោះទេ ប៉ុន្តែទោះបីជាអ្នកបញ្ចូល ក៏អ្នកនឹងមិនត្រូវទទួលពិន័យអ្វីឡើយ។

រូបថតចុះឈ្មោះឆ្នោត DV ត្រូវមានលក្ខខណ្ឌស្តង់ដារដូចនឹងរូបថតដាក់ទិដ្ឋាការអាមេរិកដែរ។ យើងនឹងបដិសេធពាក្យចុះឈ្មោះឬពាក្យស្នើសុំទិដ្ឋាការរបស់អ្នក ប្រសិនរូបថតត្រូវបានកែប្រែតាមវិធីផ្សេងៗ ឬមិនឆ្លើយតបទៅនឹងលក្ខខណ្ឌបច្ចេកទេសដូចបានពន្យល់ខាងក្រោមនេះ។ ការបញ្ចូលរូបថតដដែល ដែលត្រូវបានប្រើប្រាស់សម្រាប់ពាក្យចុះឈ្មោះឆ្នាំមុននឹងត្រូវបានបដិសេធ។ សូមមើល បញ្ចូលរូបថតឌីជីថល សម្រាប់ព័ត៌មានបន្ថែម។

៨. អាសយដ្ឋានប្រៃសណីយ៍ - អ្នកទទួល
អាសយដ្ឋានបន្ទាត់ទី ១
អាសយដ្ឋានបន្ទាត់ទី ២
ទីក្រុង
ស្រុក/តំបន់/ខេត្ត
លេខកូតតំបន់/លេខប្រៃសណីយ៍
ប្រទេស

៩. ប្រទេសដែលអ្នករស់នៅបច្ចុប្បន្ន

១០. លេខទូរស័ព្ទ (ប្រសិនមាន)

១១. អាសយដ្ឋានអ៊ីម៉ែល៖ អាសយដ្ឋានអ៊ីម៉ែលដែលអ្នកអាចប្រើប្រាស់ដោយផ្ទាល់បាន នឹងបន្តការប្រើប្រាស់ដោយផ្ទាល់ បន្ទាប់ពីយើងផ្តល់ព័ត៌មានដល់បេក្ខជនជាប់ឆ្នោតក្នុងខែឧសភានៃឆ្នាំបន្ទាប់។ ប្រសិនពាក្យចុះឈ្មោះរបស់អ្នកត្រូវបានជ្រើសរើស ហើយអ្នកឆ្លើយតបទៅនឹងការជូនដំណឹងនៃការជ្រើសរើសនោះ តាមរយៈ *Entrant Status Check* អ្នកនឹងទទួលបានអ៊ីម៉ែលទំនាក់ទំនងបន្ថែមពីក្រសួងការបរទេសសហរដ្ឋអាមេរិក ដោយជូនដំណឹងអ្នកអំពីព័ត៌មានលម្អិតនៃការសម្ភាសទិដ្ឋាការអន្តោប្រវេសន៍របស់អ្នកដែលមាននៅក្នុង *Entrant Status*

*Check* ។ ក្រសួងការបរទេសនឹងមិនផ្ញើអ៊ីម៉ែលទៅអ្នកដោយប្រាប់ថាអ្នកត្រូវបានជ្រើសរើសសម្រាប់កម្មវិធីឆ្នោត DV នោះឡើយ។ សូមមើល [សំណួរដែលសួរញឹកញាប់បំផុត](#)សម្រាប់ព័ត៌មានបន្ថែមស្តីពីដំណើរការជ្រើសរើស។

**១២.** កម្រិតការសិក្សាដែលអ្នកបានបញ្ចប់ គិតត្រឹមបច្ចុប្បន្ន (១) បឋមសិក្សា, (២) វិទ្យាល័យ គ្មានសញ្ញាបត្រ, (៣) វិទ្យាល័យ មានសញ្ញាបត្រ, (៤) សាលាវិជ្ជាជីវៈ, (៥) កម្មវិធីសិក្សាតាមសកលវិទ្យាល័យ, (៦) បរិញ្ញាបត្រពីសកលវិទ្យាល័យ, (៧) កម្មវិធីសិក្សាបញ្ចប់ថ្នាក់ឧត្តមសិក្សា, (៨) អនុបណ្ឌិត, (៩) កម្មវិធីសិក្សាថ្នាក់បណ្ឌិត, (១០) ថ្នាក់បណ្ឌិត។ សូមមើល [សំណួរដែលសួរញឹកញាប់បំផុត](#)សម្រាប់ព័ត៌មានបន្ថែមស្តីពីតម្រូវ ការលើការសិក្សា។

**១៣.** ស្ថានភាពអាពាហ៍ពិពាហ៍៖ (១) នៅលីវ (២) រៀបការហើយ ហើយប្តី/ប្រពន្ធខ្ញុំ**គ្មាន**សញ្ជាតិអាមេរិក ឬជាជនមានសិទ្ធិរស់នៅស្របច្បាប់នៅសហរដ្ឋអាមេរិក/អ្នកមានហ្គ្រីនកាត (LPR) (៣) រៀបការហើយ ហើយប្តី/ប្រពន្ធខ្ញុំមានសញ្ជាតិអាមេរិក ឬ អ្នកកាន់ហ្គ្រីនកាតនៅសហរដ្ឋអាមេរិក (៤) លែងលះ (៥) មេម៉ាយ/ពោះម៉ាយ ឬ (៦) រស់នៅបែកគ្នាស្របតាមច្បាប់។ បញ្ចូលឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ ទីក្រុងកំណើត និងប្រទេសកំណើតរបស់ប្តី/ប្រពន្ធអ្នក និងរូបថតរបស់ប្តី/ប្រពន្ធអ្នក ដែលឆ្លើយតបទៅនឹងលក្ខខណ្ឌបច្ចេកទេសដូចជារូបថតរបស់អ្នកដែរ។

ការខកខានក្នុងការបញ្ចូលប្តី/ប្រពន្ធ ឬចុះឈ្មោះបុគ្គលដែលមិនជាប្តី/ប្រពន្ធរបស់អ្នក នឹងធ្វើឱ្យអ្នកបាត់បង់សិទ្ធិជាបេក្ខជនចម្បងសម្រាប់ឆ្នោត DV និងឈានដល់ការបដិសេធចំពោះពាក្យសុំទិដ្ឋាការទាំងអស់នៅក្នុងករណីរបស់អ្នក នៅពេលសម្ភាសន៍ទិដ្ឋាការ។ អ្នកត្រូវតែបញ្ចូលព័ត៌មានប្តី/ប្រពន្ធ ទោះបីជាថ្មីៗនេះអ្នករស់នៅបែកគ្នាក៏ដោយ លើកលែងតែអ្នករស់នៅបែកគ្នាដោយស្របច្បាប់។ ការរស់នៅបែកគ្នាដោយស្របច្បាប់គឺជាការព្រមព្រៀងរវាងប្តីប្រពន្ធដែលនៅមានចំណងអាពាហ៍ពិពាហ៍ប៉ុន្តែរស់នៅបែកគ្នា ដោយមានសេចក្តីសម្រេចពីតុលាការ។ ប្រសិនអ្នកនិងប្តី/ប្រពន្ធរបស់អ្នកបានរស់នៅបែកគ្នាដោយស្របច្បាប់ ប្តី/ប្រពន្ធអ្នកនឹងមិនអាចទៅជាមួយអ្នកតាមរយៈកម្មវិធីឆ្នោត DV ឡើយ។ យើងនឹងមិនពិន័យអ្នកឡើយប្រសិនអ្នកបញ្ចូលឈ្មោះប្តី/ប្រពន្ធដែលអ្នកបានរស់នៅបែកគ្នាដោយស្របច្បាប់នោះ។ ប្រសិនអ្នករស់នៅបែកគ្នាដោយមិនមានសេចក្តីសម្រេចពីតុលាការ អ្នកត្រូវបញ្ចូលឈ្មោះប្តី/ប្រពន្ធរបស់អ្នក បើទោះបីជាអ្នកមានគម្រោងថានឹងលែងលះគ្នាមុនអ្នកចុះឈ្មោះឆ្នោត DV ក៏ដោយ។ ប្រសិនអ្នកខកខានមិនបានបញ្ចូលប្តី/ប្រពន្ធដែលមានលក្ខណៈសមស្រប យើងនឹងបដិសេធពាក្យសុំទិដ្ឋាការរបស់អ្នក។

ប្រសិនប្តី/ប្រពន្ធរបស់អ្នកមានសញ្ជាតិអាមេរិក ឬជាអ្នកមានសិទ្ធិរស់នៅស្របច្បាប់/អ្នកកាន់ហ្គ្រីនកាត (LPR) អ្នកមិនចាំបាច់បញ្ចូលឈ្មោះពួកគេឡើយ។ ប្តី/ប្រពន្ធដែលមានសញ្ជាតិអាមេរិក ឬជាអ្នកកាន់ហ្គ្រីនកាត មិនត្រូវការទិដ្ឋាការឡើយ។ហេតុដូច្នេះហើយ ប្រសិនអ្នកជ្រើសរើស "married and my spouse IS a U.S. citizen or U.S. LPR" (រៀបការហើយប្តី/ប្រពន្ធមានសញ្ជាតិអាមេរិក ឬអ្នកកាន់ហ្គ្រីនកាត) នៅក្នុងពាក្យសុំលេងឆ្នោត DV អ្នកនឹងមិនទទួលបានសំនួរបន្តទៀតដើម្បីដាក់បញ្ចូលព័ត៌មានប្តី/ប្រពន្ធរបស់អ្នកឡើយ។ សូមមើល សំណួរដែលសួរញឹកញាប់បំផុត សម្រាប់ព័ត៌មានបន្ថែមអំពីសមាជិកគ្រួសារ។

**១៤.** ចំនួនកូនក្នុងបន្ទុក៖ បញ្ចូលឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ ទីកន្លែងកំណើត និងប្រទេសកំណើតសម្រាប់កូនៗនៅក្រោមអាយុ ២១ ឆ្នាំ ហើយមិនទាន់រៀបការ មិនថាពួកគេកំពុងរស់នៅជាមួយអ្នកឬក៏អត់ ឬមានបំណងបន្តតាម ឬចូលរួមទៅរស់នៅជាមួយអ្នកឬក៏អត់ ប្រសិនអ្នកទៅរស់នៅសហរដ្ឋអាមេរិក។ សូមបញ្ចូលរូបថតកូននីមួយៗរបស់អ្នក ដោយប្រើប្រាស់លក្ខខណ្ឌបច្ចេកទេសដូចរូបថតរបស់អ្នកដែរ។

សូមកុំភ្លេចបញ្ចូល៖

- កូនៗបង្កើតដែលនៅរស់របស់អ្នកទាំងអស់
- កូនៗចិញ្ចឹមស្របច្បាប់ដែលនៅរស់របស់អ្នក និង
- កូនចុងដែលនៅរស់ មិនទាន់រៀបការ និងក្រោមអាយុ ២១ ឆ្នាំរបស់អ្នក នៅថ្ងៃចុះឈ្មោះអេឡិចត្រូនិករបស់អ្នក បើទោះបីជាអ្នកឈប់រៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយឪពុក/ម្តាយរបស់ កូនៗទាំងនោះក៏ដោយ និងបើទោះបីជាកូនៗទាំងនោះបច្ចុប្បន្នមិនបានស្នាក់នៅជាមួយអ្នក និង/ឬកូនៗទាំងនោះនឹងមិនទៅរស់នៅសហរដ្ឋអាមេរិកជាមួយអ្នកក៏ដោយ។

កូនៗដែលរៀបការហើយ និងកូនៗដែលមានអាយុចាប់ពី ២១ ឆ្នាំឡើងទៅនៅពេលអ្នកបញ្ចូលពាក្យចុះឈ្មោះរបស់អ្នក នឹងមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធីឆ្នោត DV ឡើយ។ ប៉ុន្តែច្បាប់ស្តីពីការការពារស្ថានភាពកុមារ ការពារកុមារពីការ "ហួសអាយុ" ក្នុងករណីមួយចំនួន។ ប្រសិនអ្នកបញ្ចូលពាក្យចុះឈ្មោះ DV របស់អ្នក មុនពេលកូនៗដែលមិនទាន់រៀបការរបស់អ្នកមានអាយុ ២១ ឆ្នាំ នោះ ហើយកូនៗនោះ មានអាយុ ២១ ឆ្នាំមុនពេលចេញទិដ្ឋាការ ពួកគេអាចត្រូវបានពិចារណាចាត់ចូលថានៅក្រោមអាយុ ២១ ឆ្នាំដដែល ដើម្បីដំណើរការទិដ្ឋាការ។

អ្នកមិនចាំនបាច់បញ្ចូលឈ្មោះកុមារដែលមានសញ្ជាតិអាមេរិក ឬជាអ្នករស់នៅមានសិទ្ធិស្របច្បាប់ (ហ្គ្រីនកាត) ឡើយ ដោយសារពួកគេមិនចាំបាច់ត្រូវការចេញទិដ្ឋាការឆ្នោត DV ជូនឡើយ។ យើងនឹងមិនពិន័យអ្នកឡើយក្នុងការបញ្ចូល ឬដកចេញសមាជិកគ្រួសារប្រភេទនេះ ពីពាក្យចុះឈ្មោះរបស់អ្នក។

ការខកខានក្នុងការបញ្ចូលកូនៗទាំងអស់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬបញ្ចូលអ្នកផ្សេងដែលមិនមែនជាកូនរបស់អ្នក នឹងធ្វើឱ្យអ្នកបាត់បង់សិទ្ធិជាបេក្ខជនចម្បងសម្រាប់ឆ្នោត DV និងឈានដល់ការបដិសេធចំពោះពាក្យសុំទិដ្ឋាការទាំងអស់នៅពេលសម្ភាសន៍។ សូមមើលសំណួរដែលសួរញឹកញាប់បំផុត សម្រាប់ព័ត៌មានបន្ថែមស្តីពីសមាជិកគ្រួសារ។

សូមមើល សំណួរដែលសួរញឹកញាប់បំផុត សម្រាប់ព័ត៌មានបន្ថែមអំពីការបំពេញពាក្យចុះឈ្មោះអេឡិចត្រូនិចសម្រាប់កម្មវិធីឆ្នោត DV ឆ្នាំ ២០២០។

## ការជ្រើសរើសបេក្ខជន

យោងទៅតាមការបែងចែកទិដ្ឋាការដែលមានក្នុងតំបន់និងប្រទេសនីមួយៗ ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងជ្រើសរើសបេក្ខជននីមួយៗដោយចៃដន្យតាមរយៈកុំព្យូទ័រពីចំណោមពាក្យចុះឈ្មោះដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ គ្រប់បេក្ខជនចុះឈ្មោះឆ្នោត DV ឆ្នាំ ២០២០ ត្រូវចូលទៅ *Entrant Status Check* ដោយប្រើលេខកូតបញ្ជាក់ពិសេស ដែលខ្លួនរក្សាទុកពីការចុះឈ្មោះតាមប្រព័ន្ធអ៊ីនធើណិតឆ្នោត DV ឆ្នាំ ២០២០ របស់បេក្ខជន ដើម្បីពិនិត្យមើលថាពាក្យចុះឈ្មោះរបស់ពួកគេត្រូវបានជ្រើសរើសនៅក្នុងកម្មវិធីឆ្នោត DV ឬទេ។ *Entrant Status Check* នឹងអាចចូលទៅមើលបានតាមរយៈគេហទំព័រឆ្នោត E-DV dvlottery.state.gov ចាប់ពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២០។

ប្រសិនពាក្យចុះឈ្មោះរបស់អ្នកត្រូវបានជ្រើសរើស អ្នកនឹងត្រូវមើលទំព័របញ្ជាក់មួយ (confirmation page) ដែលនឹងផ្តល់ជាការណែនាំបន្ថែម រួមទាំងព័ត៌មានស្តីពីការបង់ថ្លៃទាក់ទងនឹងអន្តោប្រវេសន៍ទៅសហរដ្ឋអាមេរិក។ *Entrant Status Check* គឺជាវិធីតែមួយគត់ដែលក្រសួងការបរទេសសហរដ្ឋអាមេរិកផ្តល់ព័ត៌មានដល់បេក្ខជនជាប់ឆ្នោតទទួលបានព័ត៌មានអំពីការជាប់ឆ្នោត DV ឆ្នាំ ២០២០ របស់ពួកគេ។ ក្រសួងការបរទេសរបស់សហរដ្ឋអាមេរិកនឹងមិនផ្ញើជាសំបុត្រ ឬផ្តល់ព័ត៌មានដល់បេក្ខជនជាប់ឆ្នោតតាមអ៊ីម៉ែលឡើយ។ ស្ថានទូត និងស្ថានកុងស៊ុលអាមេរិកនឹងមិនផ្តល់ជាបញ្ជីបេក្ខជនដែលជាប់ឆ្នោតឡើយ។ បេក្ខជនដែលមិនជាប់ក៏ត្រូវបានជូនដំណឹងតាមរយៈ *Entrant Status Check* នេះដូចគ្នា។ យើងស្នើថា អ្នកចូលទៅមើល *Entrant Status Check* ដោយខ្លួនឯង ដោយមិនគួរពឹងពាក់លើអ្នកដទៃក្នុងការពិនិត្យនិងផ្តល់ព័ត៌មានដល់អ្នកនោះឡើយ។

ដើម្បីទៅរស់សហរដ្ឋអាមេរិកបាន បេក្ខជនជាប់ឆ្នោត DV ត្រូវតែមានលក្ខណៈគ្រប់គ្រាន់ដើម្បីចូលទៅសហរដ្ឋអាមេរិក។ ទម្រង់ DS-260 ពាក្យសុំទិដ្ឋាការអន្តោប្រវេសន៍តាមអ៊ីនធើណិតនិងអត្តលេខសម្គាល់ខ្លួន តាមរយៈប្រព័ន្ធអេឡិចត្រូនិច មន្ត្រីកុងស៊ុលនឹងសួរសំណួរមួយចំនួនអំពីលក្ខណៈសម្បត្តិរបស់អ្នកដើម្បីធ្វើអន្តោប្រវេសន៍ក្រោមច្បាប់របស់សហរដ្ឋអាមេរិក។ សំណួរទាំងនោះរួមមានប្រធានបទទាក់ទងនឹងអំពើឧក្រិដ្ឋកម្មនិងសន្តិសុខជាដើម។

គ្រប់បេក្ខជនជាប់ឆ្នោតនិងសមាជិកគ្រួសារ ត្រូវតែបានផ្តល់ទិដ្ឋាការឱ្យបានមុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០២០។ ទោះជាក្រោមលក្ខខណ្ឌណាក៏ដោយ ក៏ក្រសួងការបរទេសសហរដ្ឋអាមេរិក ឬស្ថាប័ន USCIS មិនអាចចេញទិដ្ឋាការ DV ឬអនុម័តការផ្លាស់ប្តូរណាមួយក្រោយបរិច្ឆេទនេះបានឡើយ ហើយសមាជិកគ្រួសារទាំងនោះក៏មិនអាចទទួលទិដ្ឋាការ DV ដើម្បីទៅតាមក្រោយបេក្ខជនចម្បងទៅរស់នៅសហរដ្ឋអាមេរិកនៅក្រោយកាលបរិច្ឆេទនេះបានដែរ។

សូមមើលសំណួរដែលសួរញឹកញាប់បំផុតសម្រាប់ព័ត៌មានបន្ថែមស្តីពីដំណើរការជ្រើសរើស។

## ការបញ្ចូលរូបថតឌីជីថល (រូបភាព)

អ្នកអាចថតរូបឌីជីថលថ្មីមួយ ឬក៏អាចស្កេនរូបថតថ្មី (ថតក្នុងរយៈពេលប្រាំមួយខែចុងក្រោយ) ដោយកម្មវិធីស្កេនឌីជីថ ប្រសិនវារូបភាពនោះមានលក្ខខណ្ឌភិនភាគ និងលក្ខខណ្ឌបច្ចេកទេសដូចរៀបរាប់ខាងក្រោម។ រូបថតចុះឈ្មោះឆ្នោត DV ត្រូវតែមានលក្ខខណ្ឌដូចនឹងរូបថតស្នើសុំទិដ្ឋាការសហរដ្ឋអាមេរិកដែរ។ សម្រាប់គំរូរូបថតដែលអាចទទួលយកបាន សូមចុចទីនេះ។ https://travel.state.gov/content/travel/en/us-visas/visa-information-resources/photos/photo-examples.html អ្នកមិនត្រូវបញ្ចូលរូបថតចាស់ ដែលថតយូរជាង ៦ ខែ ឬរូបថតដែលគ្មានលក្ខណៈស្តង់ដារដូចរៀបរាប់ខាងក្រោមឡើយ។ ការបញ្ចូលរូបថតដដែល ដែលអ្នកធ្លាប់បានបញ្ចូលទៅក្នុងពាក្យចុះឈ្មោះឆ្នាំមុនៗ រូបថតដែលបានកែប្រែ ឬមិនត្រូវទៅតាមលក្ខខណ្ឌតម្រូវខាងក្រោមនឹងត្រូវបានបដិសេធ។

## រូបថតរបស់អ្នកត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- ពណ៌ធម្មជាតិ
- ច្បាស់

- ទំហំក្បាលបេក្ខជនគឺរវាង ១ អ៊ីញ ទៅ ១ ៣/៨ អ៊ីញ (២២ ម.ម ទៅ ៣៥ ម.ម) ឬ ៥០% ទៅ ៦៩% នៃកម្ពស់សរុបរបស់រូបថត រាប់ចាប់ពីចង្កាទៅក្បាល។ សូមមើលលក្ខខណ្ឌបច្ចេកទេសរូបថតសម្រាប់ព័ត៌មានបន្ថែម។
- ថតក្នុងរយៈពេល ៦ ខែចុងក្រោយ ដើម្បីផ្ទៀងនឹងមុខមាត់របស់អ្នកពេលបច្ចុប្បន្ន
- ផ្ទាំងខាងក្រោយពណ៌ស
- ថតចំពីមុខពេញ
- ទឹកមុខស្មើ និងបើកភ្នែក
- សម្លៀកបំពាក់ធម្មតាដែលអ្នកប្រើជារៀងរាល់ថ្ងៃ
- មិនគួរប្រើឯកសណ្ឋានឡើយនៅពេលថត លើកលែងសម្លៀកបំពាក់សាសនាដែលអ្នកប្រើរាល់ថ្ងៃ
- មិនត្រូវពាក់មួក ឬគ្របក្បាលដែលធ្វើឱ្យបាំងសក់ លើកលែងតែពាក់ក្នុងន័យសាសនាជារៀងរាល់ថ្ងៃ ផ្ទៃមុខត្រូវឱ្យឃើញពេញ ហើយការប្រើឆ្នូតក្បាលមិនត្រូវឱ្យបាំងឬចេញជាស្រមោលលើមុខឡើយ
- កាសស្តាប់ ឧបករណ៍គ្មានខ្សែ និងឧបករណ៍ស្រដៀងគ្នានេះផ្សេងៗទៀត មិនត្រូវមានក្នុងរូបថតឡើយ
- មិនត្រូវពាក់វ៉ែនតាឡើយ
- អ្នកអាចពាក់បាន ប្រសិនអ្នកប្រើឧបករណ៍ជំនួយការស្តាប់ដែលអ្នកប្រើប្រាស់ជាធម្មតា

សូមមើលគំរូរូបថតដើម្បីមើលឧទាហរណ៍រូបថតដែលអាចនិងមិនអាចទទួលយកបាន។ យើងមិនទទួលរូបថតដែលថតចម្លង ឬប័ណ្ណបើកបរស្កេន ឬឯកសារផ្លូវការផ្សេងទៀតយកបានឡើយ។ យើងក៏មិនទទួលយករូបថតប្រភេទសន្លឹក រូបថតពីទស្សនាវដ្តី រូបថតចេញពីទូរស័ព្ទ ឬរូបថតមួយជំហរឡើយ។

អ្នកត្រូវបញ្ចូលរូបថតឌីជីថលនៅពេលអ្នកចុះឈ្មោះ។ រូបថតនោះត្រូវមានលក្ខណៈដូចខាងក្រោម៖

- ជាទម្រង់ JPEG (.jpg)
- ទំហំស្មើឬតិចជាង ២៤០ គីឡូបៃត៍ (kilobytes)
- មានជ្រុងស្មើគ្នា (កំពស់ត្រូវស្មើទទឹង)
- ទំហំ ៦០០ x ៦០០ ភិចសេល (pixels)

តើអ្នកចង់ស្កេនរូបថតដែលមានស្រាប់ឬទេ? ក្រៅពីតម្រូវការរូបថតឌីជីថល រូបថតដែលមានស្រាប់ត្រូវតែ៖

- ២ x ២ (៥១ ម.ម x ៥១ ម.ម)
- ស្កេនក្នុងទំហំ ៣០០ ភិចសេលក្នុងមួយអ៊ីញ (១២ ភិចសេលក្នុងមួយមីលីម៉ែត្រ)

អ្នកអាចប្រើគេហទំព័រជំនួយរូបថតរបស់ក្រសួងការបរទេសអាមេរិកបានដើម្បី៖

- ជ្រើសរើសរូបថតឌីជីថលដែលនៅក្នុងកុំព្យូទ័ររបស់អ្នក
- កំណាត់ទំហំនិងបង្វិលប្រសិនចាំបាច់
- កាត់រូបថតឱ្យទៅជារាងការេដែលមានទំហំស្មើនឹង ៦០០ x ៦០០ ភិចសេល

**ថតរូបទារកឬកូនក្មេងពីអាយុ ១ ឆ្នាំទៅ ៣ ឆ្នាំ**

នៅពេលអ្នកថតរូបទារក ឬកូនក្មេង មិនត្រូវមានអ្នកផ្សេងនៅក្នុងរូបថតឡើយ ហើយកូនរបស់អ្នកត្រូវសម្លឹងឱ្យចំមកកាម៉េរ៉ា និងត្រូវបើកភ្នែក។

**អ្នកអាច (ទី១) ៖** អ្នកអាចដាក់ក្មេងឱ្យគេងលើក្រណាត់សំពត់ស។ ធ្វើដូចនេះ ក្បាលរបស់កូនអ្នកត្រូវបានកល់ និងបង្អើតបានជាផ្ទៃខាងក្រោយពណ៌សផងដែរ។ មិនត្រូវឱ្យមានស្រមោលលើមុខកូនរបស់អ្នកឡើយ ជាពិសេសនៅពេលអ្នកថតពីលើកូន។

**អ្នកអាច (ទី២) ៖** យកក្រណាត់ស មកគ្របកន្លែងអង្គុយក្នុងឡាន ហើយដាក់កូនរបស់អ្នកឱ្យអង្គុយដើម្បីថត។ ធ្វើដូចនេះ ក្បាលរបស់កូនអ្នកត្រូវបានកល់។

# សំណួរដែលសួរញឹកញាប់បំផុត

## លក្ខខណ្ឌតម្រូវ

### ១. តើពាក្យថា "ប្រជាជនដើម" ឬ "ប្រទេសកំណើត" មានន័យដូចម្តេច?

ប្រជាជនដើមភាគច្រើនសំដៅដល់អ្នកដែលរស់នៅក្នុងប្រទេសជាក់លាក់មួយ ដោយមិនគិតអំពីប្រទេសលំនៅ ឬសញ្ជាតិរបស់បុគ្គលនោះឡើយ។ ប្រជាជនដើមក៏អាចមានន័យថាជាអ្នកដែល មានសិទ្ធិយកប្រទេសកំណើតតាម (charged) អ្នកណាម្នាក់ ជាជាងប្រទេសដែលគេកើត ក្រោមវិធាននៃមាត្រា ២០២ (ខ) នៃច្បាប់ស្តីពីអន្តោប្រវេសន៍និងសញ្ជាតិ។

ដោយសារមានការកំណត់ចំនួនទិដ្ឋាការ ទៅលើជនអន្តោប្រវេសន៍ដែលចូលមកពីប្រទេសឬតំបន់ភូមិសាស្ត្រណាមួយ បុគ្គលនីមួយៗត្រូវយកប្រទេសមួយជាប្រទេសកំណើតរបស់ខ្លួន។ ប្រទេសកំណើតរបស់អ្នកសំដៅទៅលើប្រទេសដែលអ្នកត្រូវគេរាប់នៅក្នុងការកំណត់ទិដ្ឋាការសម្រាប់ប្រទេសនោះ។ ជាទូទៅ ប្រទេសដែលមានសិទ្ធិដាក់ពាក្យរបស់អ្នកគឺជាប្រទេសដែលអ្នកកើត។ ប៉ុន្តែ អ្នកអាចជ្រើសរើសប្រទេសដែលមានសិទ្ធិដាក់ពាក្យរបស់អ្នក ទៅតាមប្រទេសកំណើតរបស់ប្តី/ប្រពន្ធរបស់អ្នក ឬប្រទេសកំណើតរបស់ឪពុកឬម្តាយរបស់អ្នក ប្រសិនអ្នកកើតនៅក្នុងប្រទេសដែលមិនមែនជាប្រទេសកំណើតរបស់ឪពុកម្តាយអ្នក និងជាប្រទេសដែលឪពុកម្តាយរបស់អ្នកមិនមែនជាអ្នករស់នៅស្របច្បាប់ នៅពេលដែលអ្នកកើត។ ទាំងនេះគឺជាវិធីដែលមានតែបីប៉ុណ្ណោះ ក្នុងការជ្រើសរើសប្រទេសកំណើតរបស់អ្នក។

ការបញ្ចូលប្រទេសដែលមានសិទ្ធិដាក់ពាក្យ ឬប្រទេសកំណើតមិនត្រឹមត្រូវ (ឧ. ប្រទេសដែលអ្នកមិនមានទំនាក់ទំនងអ្វីទាំងអស់) អាចធ្វើឱ្យអ្នកបាត់បង់សិទ្ធិនៅក្នុងពាក្យចុះឈ្មោះរបស់អ្នក។

### ២. តើខ្ញុំនៅតែអាចដាក់ពាក្យបានឬទេ ប្រសិនបើខ្ញុំមិនកើតនៅក្នុងប្រទេសដែលមានសិទ្ធិដាក់ពាក្យផងនោះ?

អ្នកនៅតែមានសិទ្ធិដាក់ពាក្យ នៅក្នុងលក្ខខណ្ឌពីរនេះបាន។ ទីមួយ ប្រសិនប្តី/ប្រពន្ធដែលទទួលសិទ្ធិជាបេក្ខជនតាមរយៈអ្នកដែលជាអ្នកដាក់ឆ្នោត កើតនៅក្នុងប្រទេសដែលមានសិទ្ធិដាក់ពាក្យ អ្នកអាចយកប្រទេស កំណើតតាមប្តី/ប្រពន្ធអ្នកបាន។ ដោយសារតែ អ្នកដាក់ពាក្យដោយផ្អែកទៅលើប្តី/ប្រពន្ធអ្នក អ្នកនឹងត្រូវបានផ្តល់ទិដ្ឋាការអន្តោប្រវេសន៍ជូនបាន តែក្នុងករណីដែលប្តី/ប្រពន្ធរបស់អ្នក មានលក្ខណៈសម្បត្តិសមស្រប និងត្រូវបានចេញទិដ្ឋាការអន្តោប្រវេសន៍ជូនប៉ុណ្ណោះ។ អ្នកទាំងពីរត្រូវធ្វើដំណើរជាមួយគ្នាទៅសហរដ្ឋអាមេរិកដោយប្រើប្រាស់

ឆ្នោត DV នេះ។ ដូចគ្នានេះដែរ កូនដែលនៅក្នុងបន្ទុករបស់អ្នកអាច "យកប្រទេសកំណើតតាម" ប្រទេសកំណើតរបស់ឪពុកឬម្តាយបាន។

ទីពីរ អ្នកអាច "យកប្រទេសកំណើតតាម" ប្រទេសកំណើតរបស់ឪពុកឬម្តាយរបស់អ្នក ប្រសិនឪពុកនិងម្តាយរបស់អ្នកមិនបានកើត ឬរស់នៅក្នុងប្រទេសកំណើតរបស់អ្នក នៅពេលដែលអ្នកកើតទេនោះ។ ជាទូទៅ បុគ្គលម្នាក់មិនត្រូវបានបានចាត់ទុកថាជាប្រជាជននៃប្រទេសមួយ ដែលពួកគេមិនបានកើត ឬចូលសញ្ជាតិដោយស្របច្បាប់នោះទេ ប្រសិនជាពួកគេគ្រាន់តែមកទស្សនកិច្ច (មកលេង) សិក្សាក្នុងប្រទេសនោះជាបណ្តោះអាសន្ន ឬក៏ប្រចាំការបណ្តោះអាសន្នសម្រាប់មុខជំនួញ ឬការងារផ្សេងៗ ក្នុងនាមជាក្រុមហ៊ុន ឬរដ្ឋាភិបាលនៃប្រទេសមួយក្រៅពីប្រទេសដែលអ្នកកើត។

ប្រសិនជាអ្នកស្នើយកប្រទេសកំណើតតាមវិធីណាមួយខាងលើ អ្នកត្រូវផ្តល់ជាការពន្យល់នៅក្នុងពាក្យចុះឈ្មោះ E-DV ក្នុងសំណួរលេខ ៦។

ការបញ្ចូលប្រទេសដែលមានសិទ្ធិដាក់ពាក្យ ឬប្រទេសកំណើតមិនត្រឹមត្រូវ (ឧ. ប្រទេសដែលអ្នកមិនមានទំនាក់ទំនងអ្វីទាំងអស់) អាចធ្វើឱ្យអ្នកបាត់បង់សិទ្ធិនៅក្នុងពាក្យចុះឈ្មោះរបស់អ្នក ។

### ៣. ហេតុអ្វីប្រជាជនដើមនៃប្រទេសមួយចំនួនមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធីឆ្នោត DV?

គោលបំណងរបស់ឆ្នោត DV គឺផ្តល់ឱកាសអន្តោប្រវេសន៍ដល់ប្រជាជនដែលមិនមកពី "ប្រទេសដែលមានជនអន្តោប្រវេសន៍ច្រើន" (high admission)។ ច្បាប់សហរដ្ឋអាមេរិកចែងថា "ប្រទេសដែលមានជនអន្តោប្រវេសន៍ច្រើន" គឺជាប្រទេសដែលមានប្រជាជនសរុប ៥០.០០០ នាក់ ក្នុងប្រភេទទិដ្ឋាការគ្រួសារនិងការងារ ដែលបានចូលមករស់នៅក្នុងសហរដ្ឋអាមេរិកក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ។ ជារៀងរាល់ឆ្នាំ ស្ថាប័នសេវាកម្មសញ្ជាតិនិងអន្តោប្រវេសន៍របស់សហរដ្ឋអាមេរិក (USCIS) ជាអ្នកគណនាលើតួលេខនៃការទទួលចូលនិងការសុំសិទ្ធិរស់នៅរបស់ជនអន្តោប្រវេសន៍ក្នុងប្រភេទទិដ្ឋាការគ្រួសារនិងការងារ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ ដើម្បីកំណត់ប្រទេសដែលអាចចាត់ចូលជា "ប្រទេសដែលមានជនអន្តោប្រវេសន៍ច្រើន" ហើយប្រជាជនដើមនៃ ប្រទេសទាំងនេះនឹងត្រូវចាត់ទុកថាគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធីឆ្នោត DV ប្រចាំឆ្នាំផងដែរ។ ដោយសារតែការគណនានេះត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ បញ្ជីប្រទេសដែលប្រជាជនដើមមាន លក្ខណៈ សម្បត្តិគ្រប់គ្រាន់ឬមិនគ្រប់គ្រាន់អាចផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំ។

**៤. តើទិដ្ឋាការ DV ឆ្នាំ២០២០ ចំនួនប៉ុន្មានដែលនឹងផ្តល់ជូនទៅប្រជាជនដើមនៃតំបន់និងប្រទេសដែលមានសិទ្ធិដាក់ពាក្យនីមួយៗ?**

ស្ថាប័នសេវាកម្មសញ្ជាតិនិងអន្តោប្រវេសន៍របស់សហរដ្ឋអាមេរិក (USCIS) ជាអ្នកកំណត់អំពីចំនួនឆ្នោត DV តាមតំបន់ជារៀងរាល់ឆ្នាំ ស្របទៅតាមរូបមន្តដែលបានចែងនៅក្នុងមាត្រា ២០៣ (គ) នៃ INA ។ ចំនួនទិដ្ឋាការដែលក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងចេញជូនដល់ប្រជាជនដើមនៃប្រទេសនីមួយៗ នឹងត្រូវពឹងផ្អែកលើកម្រិតតាមតំបន់ដែលបានបង្កើត ចំនួនបេក្ខជនចុះឈ្មោះដែលមកពីប្រទេសនីមួយៗ និងចំនួនដែលបេក្ខជនជាប់ឆ្នោតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានទិដ្ឋាការ។ ទិដ្ឋាការដែលអាចផ្តល់ជូនទៅប្រជាជនដើមនៃប្រទេសណាមួយនឹងមិនលើសពីប្រាំពីរភាគរយនៃទិដ្ឋាការសរុបឡើយ។

**៥. តើមានលក្ខខណ្ឌតម្រូវអ្វីខ្លះសម្រាប់កម្រិតសិក្សានិងបទពិសោធន៍ការងារ?**

ច្បាប់និងបទបញ្ញត្តិរបស់សហរដ្ឋអាមេរិកតម្រូវថា រាល់បេក្ខជន DV ទាំងអស់ត្រូវតែបញ្ចប់ការសិក្សាយ៉ាងហោចណាស់ត្រឹមកម្រិតវិទ្យាល័យ ឬការសិក្សាមានតម្លៃស្មើ ឬមានបទពិសោធន៍ការងារពីរឆ្នាំ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនៅក្នុងការងារដែលតម្រូវឱ្យមានការបណ្តុះបណ្តាល ឬបទពិសោធន៍រយៈពេលពីរឆ្នាំ។ "ការសិក្សាកម្រិតវិទ្យាល័យ ឬការសិក្សាមានតម្លៃស្មើ" មានន័យថាការបញ្ចប់ការសិក្សាដោយជោគជ័យលើមុខវិជ្ជាដែលត្រូវចំណាយពេល ១២ឆ្នាំ នៅថ្នាក់បឋមសិក្សានិងមធ្យមសិក្សាពីសហរដ្ឋអាមេរិក ឬការបញ្ចប់ការសិក្សាដោយជោគជ័យក្នុងប្រទេសផ្សេងទៀតលើមុខវិជ្ជាផ្លូវការនៅថ្នាក់បឋមសិក្សានិងមធ្យមសិក្សា ដែលប្រហាក់ប្រហែលនឹងការសិក្សាថ្នាក់វិទ្យាល័យនៅសហរដ្ឋអាមេរិក។ មានតែការសិក្សាមុខវិជ្ជាផ្លូវការប៉ុណ្ណោះដែលឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវនេះបាន។ កម្មវិធីតាមប្រព័ន្ធអ៊ីនធើណិត ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ (ដូចជាសញ្ញាប័ត្រតម្លៃស្មើទូទៅ (General Equivalency Diploma G.E.D) មិនអាចទទួលយកបានឡើយ។ ភ័ស្តុតាងនៃឯកសារបញ្ជាក់ការសិក្សា ឬបទពិសោធន៍ការងារត្រូវតែដាក់ជូនមន្ត្រីកុងស៊ុលនៅពេលសម្ភាសន៍ទិដ្ឋាការ។

ប្រសិនអ្នកមិនមានលក្ខណៈដែលឆ្លើយតបទៅនឹងលក្ខខណ្ឌការសិក្សា ឬបទពិសោធន៍ការងារទេនោះ ពាក្យចុះឈ្មោះរបស់អ្នកនឹងត្រូវបានបដិសេធនៅពេលសម្ភាសន៍ទិដ្ឋាការ ហើយអ្នកនិងគ្រួសារអ្នកនឹងមិនទទួលបានទិដ្ឋាការឡើយ។

**៦. តើការងារប្រភេទណាដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ឆ្នោត DV ?**

ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងប្រើប្រាស់ទិន្នន័យ **O*Net Online** របស់ក្រសួងការងារសហរដ្ឋអាមេរិក (DOL) ដើម្បីកំណត់លក្ខខណ្ឌសមស្របលើបទពិសោធន៍ការងារ។ ប្រព័ន្ធទិន្នន័យ **O*Net Online**បែងចែកបទពិសោធន៍ការងារជា "ប្រភេទការងារ" ចំនួនប្រាំ។ ស្របពេលដែលមានការងារជាច្រើនត្រូវបានបញ្ចូលទៅក្នុងគេហទំព័ររបស់ DOL មិនមែនគ្រប់ការងារទាំងអស់មានលក្ខណៈគ្រប់គ្រាន់សម្រាប់កម្មវិធីឆ្នោត DV នោះទេ។ ដើម្បីមានលក្ខណៈគ្រប់គ្រាន់ផ្អែកតាមលក្ខខណ្ឌការងារ អ្នកត្រូវតែមានបទពិសោធន៍ពីរឆ្នាំ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ លើការងារដែលបានចាត់ចូលនៅក្នុងការត្រៀមវិជ្ជាជីវៈជាក់លាក់ (Specific Vocational Preparation (SVP) ដែលមានកម្រិត ៧.០ ឬ ខ្ពស់ជាងនេះ។

ប្រសិនអ្នកគ្មានលក្ខខណ្ឌការសិក្សា ឬបទពិសោធន៍ការងារគ្រប់គ្រាន់ទេនោះ ពាក្យចុះឈ្មោះរបស់អ្នកនឹងត្រូវបានបដិសេធនៅពេលសម្ភាសន៍ទិដ្ឋាការ ហើយអ្នកនិងគ្រួសារអ្នកនឹងមិនទទួលបានទិដ្ឋាការឡើយ។

### ៧. តើខ្ញុំអាចស្វែងរកការងារដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ឆ្នោត DV នៅក្នុងប្រព័ន្ធទិន្នន័យ O*Net Online របស់ក្រសួងការងារសហរដ្ឋអាមេរិកបានដោយដូចម្តេច?

នៅពេលអ្នកស្ថិតក្នុងគេហទំព័រ **O*Net Online** សូមអនុវត្តតាមជំហានខាងក្រោមដើម្បីកំណត់ថាការងាររបស់អ្នកមានលក្ខណៈគ្រប់គ្រាន់ឬទេ៖

១. ក្រោម "Find Occupation" ជ្រើសរើស "Job Family" ពីតារាងដែលបានទាញចុះ
២. ស្វែងរកតាមរយៈ "Job Family" ជ្រើសរើសហើយ ចុច "GO"
៣. ចុចលើលីង (link) សម្រាប់ការងារជាក់លាក់របស់អ្នក
៤. ជ្រើសរើសប្រអប់ "Job Zone" ដើម្បីស្វែងរកលេខប្រភេទការងារដែលបានកំណត់ និងកម្រិតកំណត់ការត្រៀមវិជ្ជាជីវៈជាក់លាក់ (SVP)។

ឧទាហរណ៍ ជ្រើសរើស Aerospace Engineers ។ នៅខាងក្រោម Summary Report for Aerospace Engineers ក្រោមផ្អែក Job Zone អ្នកនឹងឃើញ Job Zone 4 កម្រិត SVP ៧.០ ទៅ < ៨.០ ។ ដោយប្រើប្រាស់ឧទាហរណ៍នេះ Aerospace Engineers គឺជាការងារមានលក្ខណៈគ្រប់គ្រាន់។

សម្រាប់ព័ត៌មានបន្ថែម សូមមើល ឆ្នោត DV - គេហទំព័រអំពីបញ្ជីការងារ ។

### ៨. តើមានការកំណត់អាយុអប្បបរមានៅក្នុងការដាក់ពាក្យក្នុងកម្មវិធីឆ្នោត E-DV ឬទេ?

មិនមានការកំណត់អាយុក្នុងការដាក់ពាក្យឡើយ ប៉ុន្តែលក្ខខណ្ឌតម្រូវការការសិក្សាថ្នាក់វិទ្យាល័យ ឬបទពិសោធន៍ការងារសម្រាប់បេក្ខជនចម្បងនីមួយៗនៅពេលដាក់ពាក្យ នឹងធ្វើឱ្យបេក្ខជនភាគច្រើនដែលមានអាយុក្រោម ១៨ ឆ្នាំបាត់បង់សិទ្ធិក្នុងការដាក់ពាក្យ។

## *ការបំពេញពាក្យចុះឈ្មោះអេឡិចត្រូនិចសម្រាប់កម្មវិធីឆ្នោត DV*

### ៩. តើខ្ញុំអាចដាក់ពាក្យចុះឈ្មោះនៅពេលណាបាន?

រយៈពេលដាក់ពាក្យឆ្នោត DV ឆ្នាំ២០២០ នឹងចាប់ផ្តើមពីម៉ោង ១២៖០០ (ថ្ងៃត្រង់) Eastern Daylight Time (EDT) (GMT-4) ថ្ងៃពុធ ទី០៣ ខែតុលា ឆ្នាំ២០១៨ រហូតដល់ម៉ោង១២៖០០ (ថ្ងៃត្រង់) Eastern Standard Time (EST) (GMT-5) ថ្ងៃអង្គារ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨។ ជារៀងរាល់ឆ្នាំ មានបេក្ខជនរាប់លាននាក់បានដាក់ពាក្យចុះឈ្មោះ។ ការកំណត់រយៈពេលចុះឈ្មោះនៅកាលបរិច្ឆេទខាងលើនេះ ធានាថាបេក្ខជនត្រូវបាន ជូនដំណឹងដោយទាន់ពេលវេលា ព្រមទាំងផ្តល់ឱ្យទាំងបេក្ខជនទិដ្ឋាការ និងស្ថានទូតនិងស្ថានកុងស៊ុលរបស់ យើងក្នុងការរៀបចំនិងបញ្ចប់ករណីនីមួយៗដើម្បីផ្តល់ជាទិដ្ឋាការ។

យើងលើកទឹកចិត្តអ្នកក្នុងការដាក់ពាក្យឱ្យបានរួសរាន់ ក្នុងអំឡុងពេលចុះឈ្មោះ ។ ការចុះឈ្មោះដ៏ច្រើននៅពេលជិតបញ្ចប់នៃការចុះឈ្មោះ អាចនឹងធ្វើឱ្យប្រព័ន្ធកុំព្យូទ័រដំណើរការយឺត។ យើងនឹងមិនទទួលយកការចុះឈ្មោះក្រោយពេលថ្ងៃត្រង់ EST ថ្ងៃអង្គារ ទី០៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឡើយ។

### ១០. ខ្ញុំនៅសហរដ្ឋអាមេរិក។ តើខ្ញុំអាចចុះឈ្មោះកម្មវិធី DV បានឬទេ?

បាន។ បេក្ខជនចុះឈ្មោះអាចស្ថិតនៅសហរដ្ឋអាមេរិក ឬក្នុងប្រទេសមួយផ្សេងទៀត ហើយពាក្យចុះឈ្មោះអាចដាក់ពីទីណាក៏បាន។

### ១១. តើខ្ញុំអាចចុះឈ្មោះបានតែម្តងទេមែនទេ ក្នុងអំឡុងពេលចុះឈ្មោះ?

មែន។ ច្បាប់អនុញ្ញាតឱ្យមានការចុះឈ្មោះតែមួយប៉ុណ្ណោះសម្រាប់បេក្ខជនម្នាក់ក្នុងរដូវកាលចុះឈ្មោះនីមួយៗ។ ក្រសួងការបរទេសអាមេរិកប្រើប្រាស់បច្ចេកវិទ្យាទំនើប ដែលអាចដឹងថាមានពាក្យចុះឈ្មោះច្រើនដង។ **បេក្ខជនដែលមានពាក្យចុះឈ្មោះច្រើនជាងមួយ នឹងត្រូវបាត់បង់សិទ្ធិក្នុងកម្មវិធី DV ។**

### ១២. តើប្តី/ប្រពន្ធខ្ញុំ និងខ្ញុំអាចដាក់ពាក្យចុះឈ្មោះផ្សេងគ្នាបានឬទេ?

បាន។ ប្តី/ប្រពន្ធ អាចដាក់ពាក្យចុះឈ្មោះ ផ្សេងគ្នាបាន ប្រសិនពួកគេមានលក្ខណៈសម្បត្តិដែលសមស្រប។ ប្រសិនប្តី/ប្រពន្ធអ្នកត្រូវបានជ្រើសរើស ប្តី/ប្រពន្ធមួយទៀតមានសិទ្ធិដាក់ពាក្យជាបេក្ខជនទទួលសិទ្ធិតាមរយៈប្តី/ប្រពន្ធដែលជាប់ឆ្នោតបាន។

## ១៣. តើសមាជិកគ្រួសារណាខ្លះដែលខ្ញុំត្រូវបញ្ចូលទៅក្នុងពាក្យចុះឈ្មោះ DV របស់ខ្ញុំ?

**ប្តី/ប្រពន្ធ៖** ប្រសិនអ្នករៀបការដោយស្របច្បាប់ អ្នកត្រូវបញ្ចូលប្តី/ប្រពន្ធអ្នកមិនថាគេរស់នៅជាមួយអ្នក ឬមានបំណងធ្វើអន្តោប្រវេសន៍ទៅសហរដ្ឋអាមេរិកក៏ដោយ។ អ្នកត្រូវបញ្ចូលប្តី/ប្រពន្ធអ្នក បើទោះបីជាបច្ចុប្បន្ននេះអ្នកកំពុងរស់នៅបែកគ្នាក៏ដោយ លើកលែងតែអ្នកបានរស់នៅបែកគ្នាតាមច្បាប់។ ការរស់នៅបែកគ្នាដោយស្របច្បាប់គឺជាការព្រមព្រៀងរវាងប្តីប្រពន្ធដែលនៅមានចំណងអាពាហ៍ពិពាហ៍ប៉ុន្តែរស់នៅបែកគ្នា ដោយមានសេចក្តីសម្រេចពីតុលាការ។ ប្រសិនអ្នកនិងប្តី/ប្រពន្ធរបស់អ្នកបានរស់នៅបែកគ្នាដោយស្របច្បាប់ ប្តី/ប្រពន្ធអ្នកនឹងមិនអាចធ្វើអន្តោប្រវេសន៍ជាមួយអ្នកតាមរយៈកម្មវិធីឆ្នោត DV ឡើយ។ យើងនឹងមិនពិន័យអ្នកឡើយ ប្រសិនអ្នកបញ្ចូលឈ្មោះប្តី/ប្រពន្ធដែលអ្នកបានរស់នៅបែកគ្នាដោយស្របច្បាប់នោះ។ ប្រសិនអ្នករស់នៅបែកគ្នាដោយមិនមានសេចក្តីសម្រេចពីតុលាការ អ្នកត្រូវបញ្ចូលឈ្មោះប្តី/ប្រពន្ធរបស់អ្នក បើទោះបីជាអ្នកមានគម្រោងថានឹងលែងលះគ្នាមុនអ្នកចុះឈ្មោះឆ្នោត DV ក៏ដោយ។ ប្រសិនអ្នកខកខានមិនបានចុះឈ្មោះប្តី/ប្រពន្ធរបស់អ្នក ឬចុះឈ្មោះបុគ្គលផ្សេងដែលមិនមែនជាប្តី/ប្រពន្ធរបស់អ្នកដែលមានលក្ខខណ្ឌសមស្រប យើងនឹងបដិសេធពាក្យសុំទិដ្ឋាការរបស់អ្នក។ ប្រសិនអ្នកមិនទាន់បានរៀបការស្របច្បាប់នៅពេលចុះឈ្មោះដាក់ឆ្នោតនេះ ប៉ុន្តែមានគម្រោងរៀបការស្របច្បាប់នាពេលអនាគតវិញនោះ អ្នកមិនត្រូវចុះឈ្មោះប្តី/ប្រពន្ធនៅក្នុងកម្មវិធីឆ្នោតនោះឡើយ ដោយសារតែនេះជាមូលហេតុដែលយើងនឹងបដិសេធពាក្យចុះឈ្មោះអ្នក។ ប្រសិនអ្នកបានលែងលះគ្នាហើយ ឬប្តី/ប្រពន្ធអ្នកបានទទួលមរណភាព អ្នកមិនចាំបាច់បញ្ចូលពួកគាត់ក្នុងពាក្យចុះឈ្មោះរបស់អ្នកឡើយ។

ករណីលើកលែងតែមួយគត់សម្រាប់លក្ខខណ្ឌតម្រូវនេះគឺប្រសិនប្តី/ប្រពន្ធរបស់អ្នកមានសញ្ជាតិអាមេរិក ឬជាជនមានសិទ្ធិរស់នៅស្របច្បាប់ (ហ្គ្រីនកាត) រួចទៅហើយនោះ។ ប្រសិនប្តី/ប្រពន្ធរបស់អ្នកមានសញ្ជាតិអាមេរិក ឬជាអ្នកកាន់ហ្គ្រីនកាត អ្នកមិនចាំបាច់បញ្ចូលឈ្មោះពួកគេឡើយ។ ប្តី/ប្រពន្ធដែលមានសញ្ជាតិអាមេរិក ឬជាអ្នកកាន់ហ្គ្រីនកាត នឹងមិនតម្រូវឱ្យឬចេញទិដ្ឋាការឆ្នោត DV ជូនឡើយ។ ដូចនេះ ប្រសិនអ្នកជ្រើសរើស "married and my spouse IS a US citizen or U.S LPR (រៀបការហើយ ហើយប្តី/ប្រពន្ធខ្ញុំមានសញ្ជាតិអាមេរិក ឬជាអ្នកមានហ្គ្រីនកាត)" នៅក្នុងពាក្យចុះឈ្មោះរបស់អ្នក អ្នកនឹងមិនអាចបញ្ចូលព័ត៌មានបន្ថែមទៀតអំពីប្តី/ប្រពន្ធរបស់អ្នកទៀតបានឡើយ។

**កូនៗ៖** អ្នកត្រូវបញ្ចូលព័ត៌មានអំពីកូនៗអ្នកទាំងអស់ដែលនៅរស់ ដែលមិនទាន់រៀបការ និងដែលមានអាយុក្រោម ២១ ឆ្នាំ គិតត្រឹមពេលអ្នកដាក់ពាក្យចុះឈ្មោះ DV លើកដំបូង មិនថាពួកគេជាកូនបង្កើតរបស់អ្នក ឬជាកូនចុង (បើទោះបីជាអ្នកបានលែងលះពីឪពុក/ម្តាយរបស់កូនៗនោះក៏ដោយ) កូនៗរបស់ប្តី/ប្រពន្ធអ្នក ឬកូនៗដែលអ្នក បានយកមកចិញ្ចឹមដោយស្របទៅតាមច្បាប់របស់ប្រទេសអ្នក។ បញ្ចូលព័ត៌មានកូនៗដែលមានអាយុក្រោម ២១ ឆ្នាំ គិតត្រឹមពេលអ្នក ដាក់ពាក្យចុះឈ្មោះអេឡិចត្រូនិចលើកដំបូង បើទោះបីកូនៗទាំងនោះមិនស្នាក់នៅជាមួយអ្នក ឬអ្នកមិនមានបំណងឱ្យពួកគេចូលទៅរស់នៅក្រោមសិទ្ធិកម្មវិធីឆ្នោត DV ក៏ដោយ។ អ្នកមិនចាំបាច់បញ្ចូលព័ត៌មានអំពីកូនៗ ដែលមានសញ្ជាតិអាមេរិក ឬជាអ្នកកាន់ប្រ័ណ្ណកាតឡើយ ប៉ុន្តែប្រសិនអ្នកបញ្ចូល ក៏អ្នកនឹងមិនត្រូវបានរងពិន័យនោះឡើយ។

ឪពុកម្តាយឬបងប្អូនបង្កើតរបស់បេក្ខជនគ្មានសិទ្ធិទទួលទិដ្ឋាការ DV ក្នុងនាមជាអ្នកនៅក្នុងបន្ទុកទេ ហើយមិនគួរបញ្ចូលឈ្មោះពួកគេនៅក្នុងពាក្យចុះឈ្មោះរបស់អ្នកនោះឡើយ។

ប្រសិនអ្នកបញ្ចូលឈ្មោះសមាជិកគ្រួសារអ្នកនៅក្នុងពាក្យចុះឈ្មោះ ពួកគេមិនចាំបាច់ដាក់ពាក្យសុំទិដ្ឋាការ ឬត្រូវធ្វើអន្តោប្រវេសន៍ ឬធ្វើដំណើរជាមួយអ្នកឡើយ។ ប៉ុន្តែ ប្រសិនអ្នកខកខានក្នុងការបញ្ចូលឈ្មោះអ្នកនៅក្នុងបន្ទុក ឬបញ្ចូលឈ្មោះបុគ្គលដែលមិនមែនជាជននៅក្នុងបន្ទុកអ្នក ហើយពួកគេមានលក្ខណៈសម្បត្តិសមស្របនៅក្នុងពាក្យចុះឈ្មោះដើមរបស់អ្នកនោះ ករណីរបស់អ្នកនឹងត្រូវបានបដិសេធនៅពេលអ្នកសម្ភាសទិដ្ឋាការ ហើយនឹងមិនមានទិដ្ឋាការចេញជូនអ្នក ឬសមាជិកគ្រួសារអ្នកឡើយ។ ករណីនេះអនុវត្តតែទៅលើអ្នកដែលជាសមាជិកគ្រួសារ នៅពេលដាក់ពាក្យចុះឈ្មោះដំបូងប៉ុណ្ណោះ មិនមែនអនុវត្តចំពោះសមាជិកគ្រួសារដែលមាននៅពេលក្រោយការចុះឈ្មោះនោះឡើយ។ ប្រសិនប្តី/ប្រពន្ធរបស់អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គេនៅតែអាចដាក់ពាក្យចុះឈ្មោះផ្សេងមួយទៀត ទោះបីជាគេត្រូវបានបញ្ចូលនៅក្នុងពាក្យចុះឈ្មោះរបស់អ្នកក៏ដោយ ឱ្យតែពាក្យចុះឈ្មោះទាំងពីរនេះមានព័ត៌មានលម្អិតអំពីអ្នកនៅក្នុងបន្ទុកទាំងអស់នៅក្នុងគ្រួសារអ្នក (សូមមើលសំណួរសួរច្រើនបំផុតលេខ ១២ ខាងលើ)

### ១៤. តើខ្ញុំត្រូវតែដាក់ពាក្យចុះឈ្មោះនេះដោយខ្លួនឯងផ្ទាល់ ឬអាចមានអ្នកដទៃបំពេញជំនួសខ្ញុំបាន?

យើងជូនជាយោបល់ថា អ្នករៀបចំនិងដាក់ពាក្យចុះឈ្មោះដោយខ្លួនឯង ប៉ុន្តែអ្នកអាចឱ្យអ្នកដទៃដាក់ពាក្យចុះឈ្មោះជូនអ្នកបាន។ មិនថាអ្នកដាក់ពាក្យចុះឈ្មោះដោយខ្លួនឯង ឬតាមរយៈមេធាវី មិត្តភក្តិ សាច់ញាតិ ឬអ្នកដទៃក៏ដោយ មានតែពាក្យចុះឈ្មោះមួយប៉ុណ្ណោះជាឈ្មោះរបស់អ្នក។ ក្នុងនាមជាបេក្ខជនចុះឈ្មោះ អ្នកត្រូវទទួលខុសត្រូវដើម្បីធានាថាព័ត៌មានទាំងឡាយនៅក្នុងពាក្យចុះឈ្មោះគឺត្រឹមត្រូវនិងពេញលេញ។ ពាក្យចុះ

ឈ្មោះទាំងឡាយណាដែលមិនត្រឹមត្រូវឬមិនពេញលេញ នឹងធ្វើឱ្យអ្នកបាត់បង់សិទ្ធិក្នុងកម្មវិធី DV ។ បេក្ខជនចុះឈ្មោះគួររក្សាលេខកូតបញ្ជាក់ (confirmation number) ដោយខ្លួនឯង ដូចនេះពួកគេអាចពិនិត្យមើលលទ្ធផលពាក្យចុះឈ្មោះរបស់គេ ដោយប្រើប្រាស់ *Entrant Status Check* តាមរយៈគេហទំព័រ dvlottery.state.gov ។ បេក្ខជនដាក់ពាក្យគួររក្សាការចូលទៅកាន់គណនីអ៊ីម៉ែលដែលប្រើប្រាស់នៅក្នុងការដាក់ពាក្យ E-DV ។

**១៥. ខ្ញុំបានចុះឈ្មោះសុំទិដ្ឋាការអន្តោប្រវេសន៍ក្នុងប្រភេទមួយផ្សេងទៀត។ តើខ្ញុំនៅតែអាចដាក់ពាក្យក្នុងកម្មវិធីឆ្នោត DV បានឬទេ?**

បាន។

**១៦. តើនៅពេលណាឆ្នោត E-DV បញ្ចូលទៅក្នុងអ៊ីនធើណិត?**

អ្នកអាចចូលតាមប្រព័ន្ធអ៊ីនធើណិតអំឡុងពេលចុះឈ្មោះចាប់ផ្តើមពីម៉ោង ១២៖០០ (ថ្ងៃត្រង់) Eastern Daylight Time (EDT) (GMT-4) នៅថ្ងៃពុធ ទី០៣ ខែតុលា ឆ្នាំ២០១៨ ហើយបញ្ចប់នៅម៉ោង ១២៖០០ (ថ្ងៃត្រង់) Easter Standard Time (EST) (GMT-5) នៅថ្ងៃអង្គារ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

**១៧. តើខ្ញុំអាចទាញយក (download) និងរក្សាទុក (save) ពាក្យចុះឈ្មោះ E-DV ជាទម្រង់កម្មវិធី word ហើយបំពេញវានៅពេលក្រោយបានដែរទេ?**

ទេ។ អ្នកនឹងមិនអាចរក្សាទុកពាក្យចុះឈ្មោះ E-DV ជាកម្មវិធីមួយផ្សេងទៀតដើម្បីបំពេញនៅពេលក្រោយបានឡើយ។ ពាក្យចុះឈ្មោះ E-DV គឺមានតែជាទម្រង់អ៊ីនធើណិតប៉ុណ្ណោះ។ អ្នកត្រូវតែបំពេញព័ត៌មាននិងបញ្ចូលនៅលើអ៊ីនធើណិត។

**១៨. តើខ្ញុំអាចរក្សាទុកពាក្យចុះឈ្មោះនៅលើអ៊ីនធើណិតហើយបំពេញវានៅពេលក្រោយបានដែរទេ?**

ទេ។ ទម្រង់ពាក្យចុះឈ្មោះ E-DV ត្រូវបានកំណត់ឱ្យបំពេញនិងបញ្ចូលក្នុងពេលតែម្តងប៉ុណ្ណោះ។ អ្នកមានរយៈពេល ៦០នាទី រាប់ចាប់ពីពេលអ្នកទាញយកពាក្យមកបំពេញនិងបញ្ចូលពាក្យចុះឈ្មោះរបស់អ្នកតាមរយៈគេហទំព័រ E-DV។ ប្រសិនអ្នកបំពេញហួសពី ៦០នាទី ហើយមិនទាន់បានបញ្ចូលពាក្យចុះឈ្មោះតាមប្រព័ន្ធអេឡិចត្រូនិចទេនោះ ប្រព័ន្ធកុំព្យូទ័រនឹងលុបចោលព័ត៌មានដែលបានបញ្ចូលទាំងអស់។ ប្រព័ន្ធកុំព្យូទ័រនឹងលុបចោលរាល់ពាក្យចុះឈ្មោះទាំងឡាយណាដែលមានព័ត៌មានមិនពេញលេញ ធ្វើដូចនេះ ពាក្យសុំទាំងនោះនឹងមិនត្រូវគេរាប់ថាជាពាក្យចុះឈ្មោះដែលស្ទួនគ្នានឹងពាក្យដែលបំពេញគ្រប់គ្រាន់ហើយនៅពេលក្រោយ។ សូមអានការណែនាំ

ឆ្នោត DV ឱ្យបានច្បាស់លាស់ មុនអ្នកចាប់ផ្តើមបំពេញពាក្យលើប្រព័ន្ធអ៊ីនធើណិត ធ្វើដូចនេះអ្នកដឹងច្បាស់ថាព័ត៌មានអ្វីដែលអ្នកត្រូវការ។

## ១៩. ខ្ញុំមិនមានឧបករណ៍ស្កេនទេ។ តើខ្ញុំអាចបញ្ជូនរូបថតទៅនរណាម្នាក់នៅសហរដ្ឋអាមេរិកដើម្បីស្កេន រក្សាទុក ហើយផ្ញើតាមប្រៃសណីយ៍មកឱ្យខ្ញុំវិញ ដើម្បីខ្ញុំអាចប្រើវាសម្រាប់ពាក្យចុះឈ្មោះខ្ញុំបានឬទេ?

បាន។ ឱ្យតែរូបថតនោះមានលក្ខណៈសមស្របទៅតាមលក្ខខណ្ឌតម្រូវនៅក្នុងការណែនាំ ហើយត្រូវបានបញ្ចូលតាមប្រព័ន្ធអេឡិចត្រូនិច និងក្នុងពេលជាមួយការបំពេញពាក្យចុះឈ្មោះ E-DV។ អ្នកត្រូវត្រៀមរូបថតដែលបានស្កេនឱ្យហើយ នៅពេលអ្នកកំពុងចុះឈ្មោះតាមអ៊ីនធើណិត។ រូបថតនិងពាក្យចុះឈ្មោះនេះមិនអាចបញ្ចូលនៅពេលផ្សេងគ្នាបានឡើយ។ ពាក្យចុះឈ្មោះទាំងមូល (រូបថតនិងពាក្យ) អាចដាក់តាមប្រព័ន្ធអេឡិចត្រូនិចពីសហរដ្ឋអាមេរិក ឬពីប្រទេសផ្សេងបាន។

## ២០. ប្រសិនប្រព័ន្ធ E-DV បដិសេធពាក្យចុះឈ្មោះរបស់ខ្ញុំ តើខ្ញុំអាចចុះឈ្មោះម្តងទៀតបានទេ?

បាន។ ប្រសិនការចុះឈ្មោះរបស់អ្នកត្រូវបានបំពេញត្រឹមម៉ោង ១២ ថ្ងៃត្រង់ Eastern Standard Time (EST) (GMT-5) នៅថ្ងៃអង្គារ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨។ អ្នកនឹងមិនរងពិន័យអ្វីឡើយចំពោះការដាក់ពាក្យពីរដង ប្រសិនប្រព័ន្ធ E-DV បានបដិសេធពាក្យចុះឈ្មោះលើកទីមួយរបស់អ្នកហើយនោះ។ ដោយសារតែភាពរអាក់រអួលរបស់ប្រព័ន្ធអ៊ីនធើណិoត អ្នកអាចនឹងមិនទទួលព័ត៌មានអំពីការបដិសេធភ្លាមៗឡើយ។ អ្នកអាចសាកល្បងដាក់ពាក្យច្រើនដងតាមដែលចាំបាច់ រហូតដល់ពាក្យដែលពេញលេញត្រូវបានទទួល ហើយអ្នកទទួលបានព័ត៌មានបញ្ជាក់។ នៅពេលអ្នកទទួលបានព័ត៌មានបញ្ជាក់ហើយ មានន័យថាពាក្យចុះឈ្មោះរបស់អ្នកមានលក្ខណៈពេញលេញ ហើយអ្នកមិនគួរដាក់ពាក្យចុះឈ្មោះបន្ថែមទៀតឡើយ។

## ២១. តើខ្ញុំអាចទទួលការជូនព័ត៌មានបញ្ជាក់អេឡិចត្រូនិចពេលណា បន្ទាប់ពីខ្ញុំដាក់ពាក្យចុះឈ្មោះហើយ?

អ្នកគួរតែទទួលបានការជូនព័ត៌មានបញ្ជាក់ភ្លាមៗ រួមទាំងលេខកូតបញ្ជាក់ដែលអ្នកត្រូវតែកត់និងរក្សាទុក។ ប៉ុន្តែភាពរអាក់រអួលរបស់ប្រព័ន្ធអ៊ីនធើណិតអាចធ្វើឱ្យមានការពន្យារពេល។ អ្នកអាចចុចប៊ូតុង "Submit" ច្រើនដងតាមដែលចាំបាច់ រហូតដល់ពាក្យដែលពេញលេញត្រូវបញ្ជូន ហើយអ្នកទទួលបានការជូនព័ត៌មានបញ្ជាក់។ ប៉ុន្តែនៅពេលអ្នកទទួលបានការជូនព័ត៌មានបញ្ជាក់ហើយ អ្នកមិនត្រូវដាក់ពាក្យម្តងទៀតឡើយ។

## ២២.  ខ្ញុំបានចុចប៊ូតុង "Submit" ហើយ ប៉ុន្តែមិនបានទទួលលេខកូតបញ្ជាក់ (Confirmation Number) ទេ។ ប្រសិនខ្ញុំបញ្ចូលពាក្យចុះឈ្មោះមួយទៀត តើខ្ញុំនឹងត្រូវបានបដិសេធឬទេ?

ប្រសិនអ្នកមិនបានទទួលលេខកូតបញ្ជាក់ទេ ពាក្យចុះឈ្មោះរបស់អ្នកមិនត្រូវបានបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រឡើយ។ អ្នកត្រូវតែបញ្ចូលពាក្យចុះឈ្មោះមួយទៀត។ វានឹងមិនត្រូវបានចាត់ចូលថាស្ទួនគ្នាឡើយ។ នៅពេលដែលអ្នកទទួលបានលេខកូតបញ្ជាក់ហើយ អ្នកមិនត្រូវដាក់ពាក្យម្តងទៀតឡើយ។

## *ការជ្រើសរើស*

### ២៣. តើធ្វើដូចម្តេចទើបខ្ញុំដឹងថាខ្ញុំជាប់ឆ្នោត?

អ្នកត្រូវប្រើលេខកូតបញ្ជាក់ (confirmation number) ដើម្បីចូលទៅកាន់ការឆែកលទ្ធផលបេក្ខជន (Entrant Status Check) ដែលមាននៅក្នុងគេហទំព័រ E-DV តាមរយៈ dvlottery.state.gov ចាប់ពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។ Entrant Status Check គឺជាវិធីតែមួយគត់ដែលក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងផ្តល់ដំណឹងដល់អ្នក ប្រសិនអ្នកជាប់ឆ្នោត ក៏ដូចជាផ្តល់ការណែនាំបន្ថែមអំពីពាក្យសុំទិដ្ឋាការរបស់អ្នក និងផ្តល់ព័ត៌មានដល់អ្នកអំពីកាលបរិច្ឆេទនិងពេលវេលាសម្ភាសន៍ទិដ្ឋាការអន្តោប្រវេសន៍។ ដើម្បីប្រើប្រាស់ទិដ្ឋាការទាំងអស់បាន ក្រសួងការបរទេសអាមេរិកអាចនឹងប្រើប្រាស់ Entrant Status Check ដើម្បីជ្រើសរើសបេក្ខជនបន្ថែមទៀតចាប់ពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ តទៅ។ សូមរក្សាលេខកូតបញ្ជាក់រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ក្នុងករណីមានព័ត៌មានបន្ថែម។ មានតែគេហទំព័រក្រសួងការបរទេសអាមេរិកតែមួយគត់ ដែលបានទទួលសិទ្ធិលើពាក្យចុះឈ្មោះតាមអ៊ីនធើណិតក្នុងកម្មវិធីទិដ្ឋាការឆ្នោត DV និងការឆែកលទ្ធផលបេក្ខជន (Entrant Status Check) គឺ dvlottery.state.gov ។

ក្រសួងការបរទេសនឹងមិនទាក់ទងអ្នកដើម្បីប្រាប់ថាអ្នកជាប់ឆ្នោតនោះឡើយ (សូមមើល សំណួរសួរញឹកញាប់បំផុតលេខ ២៤)។

### ២៤. តើធ្វើដូចម្តេចទើបខ្ញុំដឹងថាខ្ញុំមិនជាប់ឆ្នោត? តើខ្ញុំនឹងត្រូវបានផ្តល់ដំណឹងអ្វីឬទេ?

ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងមិនផ្តល់ដំណឹងដល់អ្នកដោយផ្ទាល់ឡើយ ប្រសិនពាក្យចុះឈ្មោះរបស់អ្នកមិនត្រូវបានជ្រើសរើស។ អ្នកអាចឆែកលទ្ធផលពាក្យចុះឈ្មោះឆ្នោត DV ឆ្នាំ ២០២០ តាមរយៈ Entrant Status Check លើគេហទំព័រ  E-DV តាមរយៈ dvlottery.state.gov ចាប់ពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។ សូមរក្សាលេខកូតបញ្ជាក់របស់អ្នករហូតដល់យ៉ាងហោចណាស់ត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។ (ព័ត៌មានលទ្ធផលសម្រាប់កម្មវិធីឆ្នោត DV ឆ្នាំមុន DV ឆ្នាំ២០១៩ អាចចូលទៅមើលបានចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៨ ដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១៩)។

## ២៥. តើខ្ញុំត្រូវធ្វើដូចម្តេចប្រសិនខ្ញុំបាត់លេខកូតបញ្ជាក់ (confirmation number) របស់ខ្ញុំ?

អ្នកត្រូវមានលេខកូតបញ្ជាក់ដើម្បីចូលទៅ Entrant Status Check ។ ឥឡូវនេះមានកម្មវិធីដែលអាចប្រើប្រាស់បាននៅក្នុង Entrant Status Check (ESC) នៅលើគេហទំព័ររបស់ E-DV ដែលនឹងអនុញ្ញាតឱ្យអ្នកទាញយកលេខកូតបញ្ជាក់របស់អ្នក តាមរយៈអាសយដ្ឋានអ៊ីម៉ែលដែលអ្នកបានចុះឈ្មោះ ដោយបញ្ចូលនូវព័ត៌មានផ្ទាល់ខ្លួនមួយចំនួនដើម្បីបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នក។

ស្ថានទូតអាមេរិកនិងស្ថានកុងស៊ុល ព្រមទាំងមជ្ឈមណ្ឌលស្ថានកុងស៊ុលខេនថ័កគី (Kentucky Consular Center) មិនអាចឆែកស្ថានភាពឆ្នោតជូនអ្នក ឬផ្តល់ជាលេខកូតបញ្ជាក់របស់អ្នកដោយផ្ទាល់បានទេ (ក្រៅតែពីតាមរយៈកម្មវិធីទាញយក Entrant Status Check ប៉ុណ្ណោះ)។ ក្រសួងការបរទេសសហរដ្ឋអាមេរិកមិនអាចផ្តល់ជាបញ្ជីអ្នកជាប់ឆ្នោតដើម្បីបន្តដំណើរការទិដ្ឋាការបានឡើយ។

## ២៦. តើខ្ញុំនឹងទទួលបានព័ត៌មានពីក្រសួងការបរទេសសហរដ្ឋអាមេរិកតាមរយៈអ៊ីម៉ែលឬប្រៃសណីយ៍ឬទេ?

ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងមិនជូនជាលិខិតព័ត៌មានអ្វីដល់អ្នកឡើយ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកនឹងមិនផ្ញើជាអ៊ីម៉ែលដើម្បីផ្តល់ព័ត៌មានដល់បុគ្គលណាមួយថាពួកគេជាប់ឆ្នោតឡើយ ហើយក៏នឹងគ្មានគម្រោងថានឹងប្រើប្រាស់អ៊ីម៉ែលសម្រាប់គោលបំណងនេះក្នុងកម្មវិធីឆ្នោត DV ឆ្នាំ២០២០ នោះដែរ។ ប្រសិនអ្នកជាបេក្ខជនជាប់ឆ្នោត អ្នកនឹងទទួលបានតែព័ត៌មានអ៊ីម៉ែលអំពីការសម្ភាសទិដ្ឋាការរបស់អ្នកបន្ទាប់ពីអ្នកបានឆ្លើយតបទៅនឹងព័ត៌មានអំពីសេចក្តីណែនាំនៅលើ Entrant Status Check ប៉ុណ្ណោះ ។ អ៊ីម៉ែលទាំងនេះនឹងមិនមានព័ត៌មានអំពីកាលបរិច្ឆេទនិងពេលវេលាសម្ភាសន៍ឡើយ។ អ៊ីម៉ែលទាំងនេះគ្រាន់តែប្រាប់អ្នកឱ្យទៅគេហទំព័រ Entrant Status Check សម្រាប់ព័ត៌មានលម្អិតប៉ុណ្ណោះ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកអាចនឹងផ្ញើជាអ៊ីម៉ែលដោយរំលឹកដល់បេក្ខជនឆ្នោត DV ឱ្យទៅមើល ESC ដើម្បីឆែកមើលលទ្ធផលរបស់ខ្លួន។ ប៉ុន្តែអ៊ីម៉ែលទាំងនោះនឹងមិនបង្ហាញឡើយថាបេក្ខជនជាប់ឬក៏អត់នោះឡើយ។

មានតែគេហទំព័រដែលបញ្ចប់ដោយ ".gov" ប៉ុណ្ណោះ ដែលជាគេហទំព័រផ្លូវការរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក។ គេហទំព័រផ្សេងទៀត (ឧ. ដែលបញ្ចប់ដោយ ".com" ".org" ឬ ".net") គ្រាន់តែផ្តល់ជាព័ត៌មាន និងសេវាកម្មពាក់ព័ន្ធនឹងអន្តោប្រវេសន៍ និងទិដ្ឋាការប៉ុណ្ណោះ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកមិនគាំទ្រ មិនយល់ស្រប មិនលើកទឹកចិត្តអ្នកឱ្យផ្តល់ជាព័ត៌មាន ឬឯកសារណាមួយនៅលើគេហទំព័រទាំងនោះឡើយ។

អ្នកអាចទទួលអ៊ីម៉ែលពីគេហទំព័រមួយចំនួន ដែលបញ្ឆោតអ្នកឱ្យផ្ញើជាសាច់ប្រាក់ ឬផ្តល់ជាព័ត៌មានផ្ទាល់ខ្លួនជាដើម។ អ្នកអាចត្រូវសុំឱ្យបង់ប្រាក់លើពាក្យចុះឈ្មោះ និងព័ត៌មានអំពីនីតិវិធីអន្តោប្រវេសន៍ ដែលព័ត៌មានទាំងនេះមានផ្តល់ជូនដោយឥតគិតថ្លៃនៅលើគេហទំព័រក្រសួងការបរទេសសហរដ្ឋអាមេរិក travel.state.gov ឬតាមរយៈគេហទំព័រស្ថានទូត ឬស្ថានកុងស៊ុលសហរដ្ឋអាមេរិក។ បន្ថែមពីនេះ អង្គការឬគេហទំព័រទាំងនេះអាចមានបំណងចង់លួចលុយរបស់អ្នក ដោយគិតថ្លៃទៅលើសេវាកម្មពាក់ព័ន្ធនឹងឆ្នោត DV ជាដើម។ ប្រសិនអ្នកផ្ញើប្រាក់ទៅអង្គការក្រៅរដ្ឋាភិបាលនិងគេហទំព័រទាំងនេះហើយនោះ ពួកគេអាចនឹងបញ្ឈប់ទំនាក់ទំនងជាមួយអ្នកភ្លាម។ បន្ថែមពីនេះ អ្នកមិនត្រូវផ្ញើព័ត៌មានផ្ទាល់ខ្លួនទៅគេហទំព័រទាំងនេះឡើយ ដោយសារតែវាអាចត្រូវបានប្រើប្រាស់ដើម្បីលួចអត្តសញ្ញាណរបស់អ្នក ។

អ៊ីម៉ែលបោកបញ្ឆោតទាំងនេះអាចផ្ញើមកពីជនដែលបន្លំថាមានទំនាក់ទំនងជាមួយនឹងមជ្ឈមណ្ឌលស្ថានកុងស៊ុលខេនថ័កគី (Kentucky Consular Center) របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក។ **សូមចងចាំថា រដ្ឋាភិបាលអាមេរិកនឹងមិនផ្ញើអ៊ីម៉ែលដើម្បីផ្តល់ដំណឹងដល់បេក្ខជនថាពួកគេជាប់ឆ្នោតទេ ហើយក៏គ្មានគម្រោងថានឹងប្រើប្រាស់អ៊ីម៉ែលសម្រាប់កម្មវិធីឆ្នោត DV ២០២០ នោះឡើយ។ ក្រសួងការបរទេសនឹងមិនស្នើឱ្យអ្នកបញ្ជូនជាសាច់ប្រាក់តាមរយៈប្រៃសណីយ៍ ឬតាមសេវាកម្មវេរស្នើន យូនៀន (Western Union) ឡើយ។**

## ២៧. តើនឹងមានបេក្ខជនប៉ុន្មានអ្នកនឹងត្រូវបានជ្រើសរើសសម្រាប់ឆ្នោត DV ឆ្នាំ ២០២០?

សម្រាប់ឆ្នោត DV ឆ្នាំ២០២០ នឹងមានទិដ្ឋាការចំនួន ៥០.០០០ ច្បាប់។ ដោយសារតែ បេក្ខជនមួយចំនួនក្នុងចំណោមបេក្ខជន ៥០.០០០ នាក់ដំបូង ដែលបានជាប់ឆ្នោត នឹងមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទិដ្ឋាការ ឬបន្តករណីរបស់ពួកគេឱ្យឈានដល់ការចេញទិដ្ឋាការនោះ ពាក្យចុះឈ្មោះច្រើនជាង ៥០.០០០ ច្បាប់នឹងត្រូវបានជ្រើសរើសដើម្បីធានាថាចំនួនទិដ្ឋាការដែលមានទាំងអស់សុទ្ធតែត្រូវចេញជូនបេក្ខជន។ ប៉ុន្តែ ចំណុចនេះក៏មានន័យថា អាចនឹងមិនមានចំនួនទិដ្ឋាការគ្រប់គ្រាន់សម្រាប់អ្នកដែលបានជាប់ឆ្នោតដំបូងៗផងដែរ។

អ្នកអាចឆែក Entrant Status Check តាមគេហទំព័ររបស់ឆ្នោត E-DV ដើម្បីពិនិត្យមើលថាតើអ្នកត្រូវបានជ្រើសរើសដើម្បីបន្តករណីរបស់អ្នក ហើយបញ្ចូលអ្នកទៅក្នុងបញ្ជីបេក្ខជនជាប់ឆ្នោតឬទេ។ ការសម្ភាសន៍សម្រាប់កម្មវិធីឆ្នោត DV ឆ្នាំ ២០១៩ នឹងចាប់ផ្តើមនៅខែតុលា ឆ្នាំ២០១៨ សម្រាប់អ្នកជាប់ឆ្នោតដែលបានបញ្ចូលឯកសារដែលពាក់ព័ន្ធមុនការសម្ភាសន៍ និងព័ត៌មានបន្ថែមទៀតដែលបានស្នើទៅតាមសេចក្តីណែនាំដែលបានជូនជាព័ត៌មាន។ បេក្ខជនជាប់ឆ្នោតដែលបានផ្តល់ព័ត៌មានដែលតម្រូវទាំងអស់ហើយ នឹងត្រូវបានផ្តល់ជូនជាព័ត៌មាន

សម្រាប់ការសម្ភាសន៍របស់ពួកគេតាមរយៈ Entrant Status Check នៅលើគេហទំព័ររបស់ឆ្នោត E-DV ក្នុងរយៈពេលបួនទៅប្រាំមួយសប្តាហ៍ មុនសម្ភាសជាមួយនឹងមន្ត្រីកុងស៊ុល។

ជារៀងរាល់ខែ ទិដ្ឋាការនឹងត្រូវចេញជូនដល់បេក្ខជនដែលមានលក្ខណៈគ្រប់គ្រាន់ដើម្បីទទួលទិដ្ឋាការក្នុងកំឡុងខែនោះ ដរាបណានៅតែមានទិដ្ឋាការនៅសល់។ នៅពេលដែលទិដ្ឋាការឆ្នោត DV ចំនួន ៥០.០០០ ច្បាប់ ត្រូវបានចេញជូនអស់ហើយនោះ កម្មវិធីក៏នឹងបញ្ចប់ដែរ។ ចំនួនទិដ្ឋាការអាចត្រូវបានចេញជូនអស់មុនខែកញ្ញា ២០១៩។ បេក្ខជនជាប់ឆ្នោតដែលមានបំណងចង់ទទួលបានទិដ្ឋាការ ត្រូវតែត្រៀមខ្លួនឱ្យបានសមស្របសម្រាប់ករណីរបស់ពួកគេ។ **បេក្ខជនដែលត្រូវបានជ្រើសរើសដោយចៃដន្យមិនមែនមានន័យថាគេនឹងទទួលបានទិដ្ឋាការនោះឡើយ។ ការជាប់ឆ្នោតនេះគ្រាន់តែមានន័យថាអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីដាក់ពាក្យសុំទិដ្ឋាការឆ្នោត DV ប៉ុណ្ណោះ។ ប្រសិនលេខលំដាប់របស់អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ដំណើរការចុងក្រោយ អ្នកអាច មានឱកាសច្រើនដើម្បីទទួលបានទិដ្ឋាការ DV។ មានតែទិដ្ឋាការ ៥០.០០០ ច្បាប់ប៉ុណ្ណោះ ដែលនឹងចេញ ជូនបេក្ខជនដែលមានលក្ខណៈសម្បត្តិដូចនេះ។**

## ២៨. តើបេក្ខជនដែលជាប់ឆ្នោតនឹងត្រូវបានជ្រើសរើសដូចម្តេច?

**ការជូនដំណឹងនៃការជ្រើសរើសជាផ្លូវការនឹងធ្វើឡើងតាមរយៈ Entrant Status Check ដែលអាចចូលមើលបានចាប់ពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២០ នៅលើគេហទំព័រ E-DV dvlottery.state.gov ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកមិនផ្តល់ដំណឹងឬលិខិតតាមរយៈអ៊ីម៉ែល ឬប្រៃសណីយ៍ទៅបេក្ខជនឡើយ។ រាល់អ៊ីម៉ែលឬលិខិតតាមប្រៃសណីយ៍ទាំងឡាយណាដែលបញ្ជាក់ថាអ្នកត្រូវបានជ្រើសរើសដើម្បីទទួលឆ្នោត DV ដែលគ្មានប្រភពមកពីក្រសួងការបរទេសសហរដ្ឋអាមេរិក គឺមិនត្រឹមត្រូវឡើយ។ រាល់ទំនាក់ទំនងតាមអ៊ីម៉ែលដែលអ្នកទទួលបានពីក្រសួងការបរទេសសហរដ្ឋអាមេរិក នឹងប្រាប់អ្នកឱ្យទៅមើលក្នុង Entrant Status Check សម្រាប់ព័ត៌មានបន្ថែមអំពីពាក្យសុំទិដ្ឋាការរបស់អ្នក។ ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងមិនស្នើឱ្យអ្នកបញ្ជូនជាសាច់ប្រាក់តាមរយៈប្រៃសណីយ៍ ឬតាមរយៈសេវាកម្មផ្សេងទៀតដូចជាវេសស្ទើនយូនៀន (Western Union) នោះឡើយ។**

គ្រប់ពាក្យចុះឈ្មោះទាំងអស់ដែលទទួលបានពីតំបន់នីមួយៗត្រូវបានដាក់លេខដោយឡែកពីគ្នា។ នៅវដ្តកាលបញ្ចប់នៃការចុះឈ្មោះ ប្រព័ន្ធកុំព្យូទ័រនឹងជ្រើសរើសពាក្យចុះឈ្មោះដោយចៃដន្យពីបណ្តាពាក្យចុះឈ្មោះទាំងអស់ដែលបានទទួលពីតំបន់នីមួយៗ។ ក្នុងតំបន់នីមួយៗ ពាក្យចុះឈ្មោះទីមួយដែលបានជ្រើសរើសដោយចៃដន្យនឹងជាករណីដំបូងដែលបានចុះបញ្ជី។ ពាក្យចុះឈ្មោះទីពីរដែលបានជ្រើសរើសដោយចៃដន្យ នឹងជាករណីទីពីរ

ដែលបានចុះបញ្ជី។ល។ ក្នុងអំឡុងរដូវកាលចុះ គ្រប់ពាក្យចុះឈ្មោះទាំងអស់ដែលទទួលបានពីតំបន់នីមួយៗនឹងមានឱកាសស្មើៗគ្នាក្នុងការត្រូវបានជ្រើសរើស។ នៅពេលដែលពាក្យចុះឈ្មោះត្រូវបានជ្រើសរើស បេក្ខជននឹងទទួលបានព័ត៌មានអំពីការជាប់ឆ្នោតតាមរយៈ Entrant Status Check ចាប់ពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩ នៅក្នុងគេហទំព័រ E-DV dvlottery.state.gov ។ ប្រសិនអ្នកត្រូវបានជ្រើសរើស ហើយអ្នកឆ្លើយតបទៅនឹងសេចក្តីណែនាំដែលបានផ្តល់ជូនតាមអ៊ីនធើណិតនៅលើ Entrant Status Check មជ្ឈមណ្ឌលស្ថានកុងស៊ុលខេនថ៍កគី នៃក្រសួងការបរទេសសហរដ្ឋអាមេរិក នឹងដំណើរការករណីរបស់អ្នក រហូតដល់បេក្ខជនជាប់ឆ្នោតត្រូវបានណែនាំដល់ការសម្ភាសទិដ្ឋាការនៅស្ថានទូត ឬស្ថានកុងស៊ុលសហរដ្ឋអាមេរិក ឬរហូតដល់បេក្ខជនដែលនៅសហរដ្ឋអាមេរិក ដែលកំពុងដាក់ពាក្យសុំសិទ្ធិរស់នៅ បានដាក់ពាក្យនៅការិយាល័យ USCIS។

## ២៩. ពេលនេះខ្ញុំស្ថិតនៅសហរដ្ឋអាមេរិក។ ប្រសិនជាប់ឆ្នោត តើខ្ញុំអាចសុំសិទ្ធិរស់នៅ នៅឯ USCIS បានទេ?

អាចបាន។ ក្នុងករណីដែលអ្នកមានលក្ខណៈសម្បត្តិសមស្របក្នុងការសុំសិទ្ធិរស់នៅ ក្រោមបទបញ្ញត្តិនៃមាត្រា ២៤៥ នៃច្បាប់ស្តីពីអន្តោប្រវេសន៍និងសញ្ជាតិ (INA) អ្នកអាចដាក់ពាក្យនៅ USCIS ដើម្បីសុំសិទ្ធិជាអ្នករស់នៅអចិន្ត្រៃយ៍។ អ្នកត្រូវប្រាកដថា USCIS អាចដំណើរការករណីរបស់អ្នកបានដូចជា ការដាក់ពាក្យសុំនៅបរទេសណាមួយសម្រាប់ប្តី/ប្រពន្ធ ឬសម្រាប់កូនៗក្រោមអាយុ ២១ ឆ្នាំ មុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ដោយសារតែប្រសិនកាលបរិច្ឆេទនេះមកដល់ មានន័យថាសិទ្ធិរបស់អ្នកនៅក្នុងកម្មវិធីឆ្នោត DV ឆ្នាំ២០២០ នឹងផុតសុពលភាព។ ក្រសួងការបរទេសសហរដ្ឋអាមេរិកនឹងមិនអនុម័ត ឬធ្វើការផ្លាស់ប្តូរណាមួយសម្រាប់កម្មវិធី DV ឆ្នាំ២០២០ ឡើយ ចាប់ពីយប់ EDT នៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២០ ទោះក្រោមលក្ខខណ្ឌណាក៏ដោយ។

## ៣០. ប្រសិនខ្ញុំជាប់ឆ្នោត តើខ្ញុំមាន សិទ្ធិយូរប៉ុណ្ណាដើម្បីដាក់ពាក្យសុំទិដ្ឋាការ DV?

ប្រសិនអ្នកជាប់ឆ្នោតក្នុងកម្មវិធីឆ្នោត DV ២០២០ អ្នកមានសិទ្ធិដាក់ពាក្យសុំទិដ្ឋាការតែត្រឹមក្នុងអំឡុងឆ្នាំសារពើពន្ធ ២០២០ របស់រដ្ឋាភិបាលសហរដ្ឋអាមេរិកប៉ុណ្ណោះ ដែលចាប់ផ្តើមពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។ យើងស្នើថាបេក្ខជនដែលជាប់ឆ្នោត ដាក់ពាក្យសុំទិដ្ឋាការឱ្យបានឆាប់បំផុតនៅពេលដែលលេខលំដាប់កម្មវិធីឆ្នោតរបស់ពួកគេមានសុពលភាព។

**ដោយគ្មានករណីលើកលែង គ្រប់បេក្ខជនជាប់ឆ្នោតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវតែទទួលទិដ្ឋាការ ឬសុំសិទ្ធិរស់នៅឱ្យបានមុន បញ្ចប់ឆ្នាំសារពើពន្ធ។** សូមបញ្ជាក់ថាគ្មានការបន្តអត្ថប្រយោជន៍ឆ្នោត DV ទៅឆ្នាំបន្ទាប់សម្រាប់បេក្ខជនជាប់ឆ្នោត ប៉ុន្តែមិនបានទទួលទិដ្ឋាការត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ (នៅពេលបញ្ចប់ឆ្នាំសារពើពន្ធ) នោះឡើយ។ បន្ថែមពីនេះ ប្តី/ប្រពន្ធនិងកូនៗដែលទទួលបានសិទ្ធិតាមរយៈបេក្ខជនជាប់ឆ្នោត DV

ឆ្នាំ២០២០ អាចទទួលបានទិដ្ឋាការនៅក្នុងប្រភេទឆ្នោត DV ចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ដល់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ប៉ុណ្ណោះ។ បេក្ខជនដែលបានដាក់ពាក្យពីក្រៅប្រទេសនឹងទទួលបានសេចក្តីជូនដំណឹងអំពីការសម្ភាសពីក្រសួងការបរទេសសហរដ្ឋអាមេរិក តាមរយៈ Entrant Status Check នៅលើគេហទំព័រ E-DV ក្នុងរយៈពេលបួនទៅប្រាំមួយសប្តាហ៍មុនការសម្ភាសន៍ដែលបានកំណត់។

### ៣១. ប្រសិនបេក្ខជនជាប់ឆ្នោតស្លាប់ តើករណីនេះនឹងមានបញ្ហាអ្វីឬទេ?

ប្រសិនបេក្ខជនជាប់ឆ្នោតស្លាប់ មុនបេក្ខជននោះធ្វើដំណើរទៅសហរដ្ឋអាមេរិក ឬសុំសិទ្ធិរស់នៅ ករណី DV នោះ នឹងត្រូវបិទដោយស្វ័យប្រវត្តិ។ ប្តី/ប្រពន្ធឬកូនៗដែលទទួលសិទ្ធិតាមរយៈបេក្ខជនជាប់ឆ្នោតដែលស្លាប់នោះនឹងអស់សិទ្ធិទទួលឆ្នោតទិដ្ឋាការ DV ។ រាល់ទិដ្ឋាការណាដែលបានចេញជូនពួកគេនឹងត្រូវបានដកទុកវិញ។

## *ការបង់ថ្លៃ*

### ៣២. តើខ្ញុំត្រូវបង់ថ្លៃអស់ប៉ុន្មាន ដើម្បីអាចចុះឈ្មោះកម្មវិធីឆ្នោត DV បាន?

**បេក្ខជនដាក់ពាក្យចុះឈ្មោះអេឡិចត្រូនិចនឹងមិនត្រូវចំណាយលើថ្លៃអ្វីនោះឡើយ។** ប៉ុន្តែ ប្រសិនអ្នកត្រូវបានជ្រើសរើស ហើយដាក់ពាក្យសុំទិដ្ឋាការឆ្នោត DV អ្នកត្រូវបង់ថ្លៃទិដ្ឋាការ នៅពេលដាក់ពាក្យសុំទិដ្ឋាការ និងការសម្ភាសដោយផ្ទាល់ទៅបេឡាករកុងស៊ុល នៅឯស្ថានកុងស៊ុល ឬស្ថានទូតសហរដ្ឋអាមេរិក។ ប្រសិនអ្នកជាបេក្ខជនជាប់ឆ្នោតស្ថិតនៅសហរដ្ឋអាមេរិក ហើយអ្នកដាក់ពាក្យតាម USCIS ដើម្បីសុំសិទ្ធិរស់នៅ អ្នកនឹងត្រូវបង់ថ្លៃនានាដែលតម្រូវដោយផ្ទាល់ទៅ USCIS ។ ប្រសិនអ្នកត្រូវបានជ្រើសរើស អ្នកនឹងទទួលបានព័ត៌មានលម្អិតអំពីការបង់ថ្លៃដែលតម្រូវសម្រាប់ពាក្យសុំទិដ្ឋាការ DV និងអន្តោប្រវេសន៍ ដោយភ្ជាប់មកនូវការណែនាំ ដែលបានផ្តល់ជូនតាមរយៈគេហទំព័រ E-DV គឺ dvlottery.state.gov ។

### ៣៣. តើខ្ញុំត្រូវបង់ថ្លៃទិដ្ឋាការអន្តោប្រវេសន៍ DV ដោយដូចម្តេចនិងនៅទីណា ប្រសិនខ្ញុំជាប់ឆ្នោត?

ប្រសិនអ្នកបានជាប់ឆ្នោតហើយ អ្នកនឹងទទួលបានការណែនាំសម្រាប់ដំណើរការពាក្យសុំទិដ្ឋាការ DV តាមរយៈ Entrant Status Check នៅគេហទំព័រ dvlottery.state.gov ។ អ្នកនឹងត្រូវបង់ថ្លៃទិដ្ឋាការឆ្នោត DV និងអន្តោប្រវេសន៍ទាំងអស់ដោយផ្ទាល់នៅស្ថានទូត ឬស្ថានកុងស៊ុលសហរដ្ឋអាមេរិកនៅពេលដាក់ពាក្យសុំទិដ្ឋាការ។ បេឡាករកុងស៊ុលនឹងផ្តល់ជូនអ្នកនូវបង្កាន់ដៃបង់ប្រាក់របស់រដ្ឋាភិបាលសហរដ្ឋអាមេរិកមកវិញភ្លាមៗ។ អ្នកមិនត្រូវផ្ញើប្រាក់សម្រាប់ថ្លៃឆ្នោត DV ទៅនរណាម្នាក់តាមរយៈប្រៃសណីយ៍ តាមវេសស្ទើនយូនៀន ឬសេវាកម្មដឹក

ជញ្ជូនផ្សេងទៀតឡើយ ប្រសិនអ្នកកំពុងដាក់ពាក្យទិដ្ឋាការអន្តោប្រវេសន៍នៅស្ថានទូត ឬស្ថានកុងស៊ុលសហរដ្ឋអាមេរិក។

ប្រសិនអ្នកត្រូវបានជ្រើសរើសហើយអ្នកកំពុងស្ថិតនៅសហរដ្ឋអាមេរិក ហើយមានគម្រោងដាក់ពាក្យសុំសិទ្ធិរស់នៅជាមួយ USCIS អ្នកអាចចូលទៅមើលនៅទំព័រព័ត៌មានណែនាំតាមរយៈ Entrant Status Check នៅគេហទំព័រ [dvlottery.state.gov](dvlottery.state.gov) ដែលមានព័ត៌មានណែនាំអំពីវិធីបញ្ជូនប្រាក់បង់ថ្លៃលទ្ធផលឆ្នោត DV ទៅធនាគារនៅសហរដ្ឋអាមេរិក។

### ៣៤. ប្រសិនខ្ញុំដាក់ពាក្យ DV ប៉ុន្តែមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តើខ្ញុំនឹងទទួលប្រាក់ដែលខ្ញុំបានបង់សម្រាប់ទិដ្ឋាការ មកវិញឬទេ?

ទេ។ ការបង់ថ្លៃទិដ្ឋាការនឹងមិនសងទៅបេក្ខជនវិញឡើយ។ អ្នកត្រូវមានគ្រប់លក្ខណៈសម្បត្តិទាំងអស់សម្រាប់ទិដ្ឋាការ ដូចបានលម្អិតនៅក្នុងសេចក្តីណែនាំទាំងនេះ។ ប្រសិនមន្ត្រីកុងស៊ុលកំណត់ថាអ្នកមិនមានលក្ខណៈសមស្របដើម្បីទទួលទិដ្ឋាការ ឬអ្នកមិនមានលក្ខណៈគ្រប់គ្រាន់ក្រោមច្បាប់របស់សហរដ្ឋអាមេរិកទេនោះ មន្ត្រីកុងស៊ុលនឹងមិនអាចចេញទិដ្ឋាការជូនអ្នកបានឡើយ ហើយអ្នកនឹងមិនផ្តល់ជូនថ្លៃដែលបានបង់វិញនោះឡើយ។

## *ភាពមិនមានលក្ខណៈសម្បត្តិសមស្រប*

### ៣៥. ក្នុងនាមជាបេក្ខជនឆ្នោត DV តើខ្ញុំអាចទទួលការលើកលែងលើករណីនៃភាពមិនមានលក្ខណៈសម្បត្តិសមស្របសម្រាប់ទិដ្ឋាការបានឬទេ? តើពាក្យសុំការលើកលែងរបស់ខ្ញុំទទួលបានដំណើរការពិសេសណាមួយឬទេ?

បេក្ខជនឆ្នោត DV ទាំងអស់ត្រូវអនុវត្តគ្រប់ករណីនៃភាពមិនមានលក្ខណៈសម្បត្តិសមស្របសម្រាប់ទិដ្ឋាការអន្តោប្រវេសន៍ ដែលបានបញ្ជាក់ក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍និងសញ្ជាតិ (INA) ។ មិនមានមាត្រាពិសេសណាមួយស្តីពីការលើកលែងចំពោះករណីនៃភាពមិនមានលក្ខណៈសម្បត្តិសមស្របសម្រាប់ទិដ្ឋាការក្រៅពីចំណុចដែលបានបញ្ជាក់នៅក្នុង INA ឬដំណើរការពិសេសណាមួយសម្រាប់ការស្នើសុំការលើកលែងនោះឡើយ។ មាត្រាទូទៅមួយចំនួនទាក់ទងនឹងការលើកលែង សម្រាប់អ្នកដែលមានសាច់ញាតិជិតស្និទ្ធ ដែលមានសញ្ជាតិអាមេរិក ឬអ្នកកាន់ហ្គ្រីនកាត អាចផ្តល់ជូនទៅបេក្ខជនឆ្នោត DV បានក្នុងករណីមួយចំនួន ប៉ុន្តែដោយសារតែរយៈពេលមានកម្រិតនៅក្នុងកម្មវិធីឆ្នោត DV អាចបង្កលក្ខណៈលំបាកសម្រាប់បេក្ខជនក្នុងការទទួលបានអត្ថប្រយោជន៍ពីមាត្រាទាំងនេះ។

## *ការក្លែងបន្លំនិងការបោកបញ្ឆោតទាក់ទងនឹងឆ្នោត DV*

### ៣៦. តើខ្ញុំអាចរាយការណ៍អំពីការក្លែងបន្លំតាមអ៊ីនធើណិត ឬអ៊ីម៉ែលដែលមិនបានស្នើសុំ ដោយដូចម្តេច?

សូមចូលទៅកាន់គេហទំព័រ econsumer.gov ដែលគ្រប់គ្រងដោយគណៈកម្មការពាណិជ្ជកម្មសហព័ន្ធ សហការជាមួយនឹងភ្នាក់ងារការពារអ្នកប្រើប្រាស់មកពីបណ្តាប្រទេសចំនួន៣៦។ អ្នកក៏អាចរាយការណ៍អំពីក្លែងបន្លំទៅ មជ្ឈមណ្ឌលបណ្តឹងឧក្រិដ្ឋកម្មអ៊ីនធើណិត របស់ប៉ូលីសស៊ើបអង្កេតសហព័ន្ធ (FBI) ផងដែរ។ ដើម្បីដាក់ពាក្យបណ្តឹងអំពីអ៊ីម៉ែលដែលមិនបានស្នើសុំ អ្នកអាចប្រើប្រាស់កម្មវិធីដាក់ពាក្យបណ្តឹង "Telemarking and Spam" នៅលើគេហទំព័រ econsumer.gov ឬចូលទៅអ៊ីម៉ែលពាណិជ្ជកម្មក្លែងបន្លំ ("Spam") នៃក្រសួងការបរទេស សម្រាប់ព័ត៌មានបន្ថែម។

## *ស្ថិតិឆ្នោត DV*

### ៣៧. តើមានទិដ្ឋាការចំនួនប៉ុន្មាននឹងត្រូវចេញជូនបេក្ខជនសម្រាប់ DV ឆ្នាំ២០២០?

យោងតាមច្បាប់ មានទិដ្ឋាការសរុបចំនួន ៥៥.០០០ ច្បាប់នឹងត្រូវផ្តល់ជូនទៅបេក្ខជនដែលមានលក្ខណៈសម្បត្តិសមស្រប។ ប៉ុន្តែក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៧ សភាសហរដ្ឋអាមេរិកបានអនុម័តច្បាប់ Nicraguan Adjustment and Central American Relief Act (NACARA) ដែលបានចែងថាចាប់ពីឆ្នោត DV ឆ្នាំ ១៩៩៩ មក រហូតដល់រយៈពេលមួយដែលចាំបាច់ ឆ្នោតចំនួន ៥.០០០ ច្បាប់ក្នុងចំណោមឆ្នោត DV ៥៥.០០០ ច្បាប់ ដែលបានបែងចែកជារៀងរាល់ឆ្នាំ នឹងត្រូវបានផ្តល់ជូនសម្រាប់ការប្រើប្រាស់ក្រោមកម្មវិធី NACARA។ ការកាត់បន្ថយជាក់ស្តែងនៃការកម្រិតនេះ ចាប់ផ្តើមពីឆ្នោត DV ឆ្នាំ ២០០០ ហើយនឹងនៅតែអនុវត្តក្នុងកម្មវិធីឆ្នោត ២០២០ ផងដែរ ដូចនេះ ទិដ្ឋាការចំនួន ៥០.០០០ ច្បាប់ នៅតែត្រូវបានប្រើសម្រាប់កម្មវិធីឆ្នោត DV ដែលបានរៀបរាប់នៅក្នុងសេចក្តីណែនាំនេះ។

## *សំណួរផ្សេងៗ*

### ៣៨.ប្រសិនខ្ញុំទទួលបានទិដ្ឋាការតាមរយៈកម្មវិធីឆ្នោត DV តើរដ្ឋាភិបាលសហរដ្ឋអាមេរិកនឹងចេញថ្លៃហោះហើររបស់ខ្ញុំទៅសហរដ្ឋអាមេរិក ជួយខ្ញុំរកកន្លែងស្នាក់នៅនិងការងារ និង/ឬផ្តល់ការថែទាំសុខភាព ឬឧបត្ថម្ភធនធានណាមួយរហូតដល់ខ្ញុំអាចរស់នៅបានដោយសមស្របដែរឬទេ?

ទេ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកនឹងមិនផ្តល់សេវាកម្មណាមួយខាងលើនេះឡើយ ប្រសិនអ្នកទទួលបានទិដ្ឋាការតាមរយៈកម្មវិធីឆ្នោត DV នោះ។ ប្រសិនអ្នកត្រូវបានជ្រើសរើសដើម្បីដាក់ពាក្យឆ្នោត DV អ្នកត្រូវបង្ហាញថាអ្នកនឹងមិនក្លាយជាជនដែលពឹងផ្អែកលើរដ្ឋាភិបាលនៅក្នុងសហរដ្ឋអាមេរិកមុននឹងអ្នកត្រូវបានផ្តល់ទិដ្ឋាការជូនឡើ

យ។ ភ័ស្តុតាងនេះអាចពឹងផ្អែកលើកត្តាទ្រព្យសម្បត្តិផ្ទាល់ខ្លួន ពាក្យធានាថវិកា (ទម្រង់ I-134) ដាក់ជូនដោយសាច់ញាតិ ឬមិត្តភក្តិដែលមានទីលំនៅនៅសហរដ្ឋអាមេរិក ការផ្តល់ជាការងារពីនិយោជកនៅសហរដ្ឋអាមេរិក ឬភ័ស្តុតាងផ្សេងទៀត។

## បញ្ជីប្រទេស/តំបន់តាមភូមិសាស្ត្រដែលប្រជាជនដើមមានសិទ្ធិនៅក្នុងកម្មវិធីឆ្នោត DV ឆ្នាំ ២០២០

បញ្ជីខាងក្រោមនេះបង្ហាញអំពីប្រទេសដែលប្រជាជនដើមមានសិទ្ធិនៅក្នុងកម្មវិធីឆ្នោត DV ឆ្នាំ ២០២០ ដែលដាក់តាមក្រុមតំបន់ភូមិសាស្ត្រ។ តំបន់រណបនៅក្រៅប្រទេសត្រូវបានបញ្ចូលនៅក្នុងតំបន់របស់ប្រទេសចម្បង។ USCIS បានកំណត់ប្រទេសដែលប្រជាជនដើមមិនមានសិទ្ធិក្នុងកម្មវិធីឆ្នោត DV ឆ្នាំ ២០២០ យោងទៅតាមរូបមន្តក្នុងមាត្រា ២០៣ (គ) នៃច្បាប់ INA ។ ប្រទេសដែលមានប្រជាជនដើមគ្មានសិទ្ធិនៅក្នុងកម្មវិធីឆ្នោត DV (ដោយសារប្រទេសទាំងនេះជាប្រភពចម្បងនៃអន្តោប្រវេសន៍ប្រភេទគ្រួសារនិងការងារ ឬ "ប្រទេសដែលមានអន្តោប្រវេសន៍ច្រើន") ត្រូវបានកំណត់ជាបន្តបន្ទាប់ពីបញ្ជីតាមតំបន់នេះ។

### តំបន់អាហ្វ្រិក

អាល់ហ្សេរីយ៉ា
អង់ហ្គោឡា
បេណាំង
បុតស្វាណា
បួគីណាហ្វាសូ
ប៊ូរុនឌី
កាមេរូន
កាប់វែរ
សាធារណរដ្ឋអាហ្វ្រិកកណ្តាល
ឆាដ
កូម័រ
កុងហ្គោ
សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ
កូតឌីវ័រ
ជីប៊ូទី
អេហ្ស៊ីប*
ហ្គីណេអេក្វាទ័រ
អេរីត្រេ
អេត្យូពី
ហ្គាបុង
ម៉ាដាហ្គាស្កា
ម៉ាឡាវី
ម៉ាលី
ម៉ូរីតានី
ម៉ូរីស
ម៉ារ៉ុក
ម៉ូសំប៊ិក
ណាមីប៊ី
នីហ្សេ
រវ៉ាន់ដា
សៅតូម៉េនិងប្រាំងស៊ីប
សេណេហ្កាល់
សីស្ហែល
សៀរ៉ាឡេអូន
សូម៉ាលី
អាហ្វ្រិកខាងត្បូង
ស៊ូដង់ខាងត្បូង
ស៊ូដង់
ស្វាស៊ីឡង់
តង់សានី

ហ្គំប៊ី
ហ្គាណា
ហ្គីណេ
ហ្គីណេប៊ីស្សូ
កេនយ៉ា
ឡេសូតូ
លីបេរីយ៉ា
លីប៊ី
តូហ្គោ
ទុយនេស៊ី
អ៊ូហ្គង់ដា
សំប៊ី
ស៊ីមបាវ៉េ

* បុគ្គលដែលបានកើតនៅក្នុងតំបន់ដែលបានគ្រប់គ្រងមុនខែមិថុនា ឆ្នាំ ១៩៦៧ ដោយអ៊ីស្រាអែល ហ្សកដានី ស៊ីរី និងអេហ្ស៊ីប ត្រូវយកប្រទេសកំណើតទៅតាមលំដាប់លំដោយពី អ៊ីស្រាអែល ហ្សកដានី ស៊ីរី និងអេហ្ស៊ីប ។ បុគ្គលដែលកើតនៅតំបន់ហ្គាហ្សាត្រូវយកប្រទេសកំណើតទៅតាមប្រទេសអេហ្ស៊ីប។ បុគ្គលដែលកើតនៅក្នុងតំបន់វេសត៍បេងក៍ (West Bank) ត្រូវយកប្រទេសកំណើតទៅតាមប្រទេសហ្សកដានី។ បុគ្គលដែលកើតនៅក្នុងតំបន់ហ្គោលេនហៃត៍ (Golan Heights) ត្រូវយកប្រទេសកំណើតទៅតាមប្រទេសស៊ីរី។

ក្នុងទ្វីបអាហ្វ្រិក ប្រជាជនដើមមកពីនីហ្សេរីយ៉ាសិទ្ធិនៅក្នុងកម្មវិធីឆ្នោត DV នៅឆ្នាំនេះឡើយ។

**<u>តំបន់អាស៊ី</u>**

អាហ្វហ្គានីស្ថាន
បារ៉ែន
ប៊ូតង់
ព្រុយណេ
ភូមា
កម្ពុជា
តំបន់រដ្ឋបាលពិសេសហុងកុង **
ឥណ្ឌូណេស៊ី
អ៊ីរ៉ង់
អ៊ីរ៉ាក់
អ៊ីស្រាអែល *
ជប៉ុន
ម៉ាឡេស៊ី
ម៉ាល់ឌីវ
ម៉ុងហ្គោលី
នេប៉ាល់
កូរ៉េខាងជើង
អូម៉ង់
កាតា
អារ៉ាប៊ីសាអូឌីត
សឹង្ហបូរី
ស្រីលង្កា
ស៊ីរី *
តៃវ៉ាន់ **

| | |
|---|---|
| ហ្ស៊កដានី * | ថៃ |
| កូវ៉ែត | ទីម័រ |
| ឡាវ | អេមីរ៉ាតអារ៉ាប់រួម |
| លីបង់ | យេម៉ែន |

* បុគ្គលដែលបានកើតនៅក្នុងតំបន់ដែលបានគ្រប់គ្រង មុនខែមិថុនា ឆ្នាំ ១៩៦៧ ដោយអ៊ីស្រាអែល ហ្ស៊កដានី ស៊ីរី និងអេហ្ស៊ីប ត្រូវយកប្រទេសកំណើតទៅតាមលំដាប់លំដោយពី អ៊ីស្រាអែល ហ្ស៊កដានី ស៊ីរី និងអេហ្ស៊ីប ។ បុគ្គលដែលកើតនៅតំបន់ហ្គាហ្សាត្រូវយកប្រទេសកំណើតទៅតាមប្រទេសអេហ្ស៊ីប។ បុគ្គលដែលកើតនៅក្នុងតំបន់វេសទ៍បេងក៍ (West Bank) ត្រូវយកប្រទេសកំណើតទៅតាមប្រទេសហ្ស៊កដានី។ បុគ្គលដែលកើតនៅក្នុងតំបន់ហ្គោលេនហៃត៍ (Golan Heights) ត្រូវយកប្រទេសកំណើតទៅតាមប្រទេសស៊ីរី។

** ហុងកុង S.A.R (តំបន់អាស៊ី) ម៉ាកាវ S.A.R (តំបន់អឺរ៉ុបយកតាមព័រទុយហ្គាល់) និងតៃវ៉ាន់ (តំបន់អាស៊ី) **មានសិទ្ធិ** ហើយត្រូវបានបញ្ចូលនៅក្នុងបញ្ជី។ សម្រាប់តែគោលបំណងកម្មវិធីឆ្នោត DV ប៉ុណ្ណោះ ដែលបុគ្គលដែលកើតនៅម៉ាកាវ S.A.R ទាញយកសិទ្ធិពីព័រទុយហ្គាល់។

***បុគ្គលដែលកើតនៅបណ្តាប្រជុំកោះហាបូមី ស៊ិកូតាន គូណាស៊ីរី និងអេតូរូហ្វូនៃនឹងយកទៅតាមប្រទេសជប៉ុន។ បុគ្គលដែលកើតនៅខេត្តសាខាលីនខាងត្បូងនឹងយកទៅតាមប្រទេសរុស្ស៊ី។

ប្រជាជនដើមនៃបណ្តាតំបន់ប្រទេសអាស៊ីនេះ**មិនមាន**សិទ្ធិនៅក្នុងកម្មវិធីឆ្នោត DV ឆ្នាំនេះឡើយ៖ បង់ក្លាដែស ចិន (ដីគោក) ឥណ្ឌា ប៉ាគីស្ថាន កូរ៉េខាងត្បូង ហ្វីលីពីន និងវៀតណាម។

## <u>តំបន់អឺរ៉ុប</u>

| | |
|---|---|
| អាល់បានី | លីទុយអានី |
| អង់ដូរ៉ា | លុចសំបួ |
| អាមេនី | ម៉ាកាវ តំបន់រដ្ឋបាលពិសេស ** |
| អូទ្រីស | ម៉ាសេដ្វាន |
| អាស៊ែបៃហ្សង់ | ម៉ាល់ត៍ |
| បេឡារុស | ម៉ុលដូវ៉ា |
| បែលហ្ស៊ិក | ម៉ូណាកូ |
| បូស្នីនិងហើហ្សេហ្គោវីណា | ម៉ុងតេណេហ្គ្រោ |

ប៊ុលហ្គារី
ក្រូអាស៊ី
ស៊ីប
សាធារណរដ្ឋឆែក
ដាណឺម៉ាក (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
អេស្តូនី
ហ្វាំងឡង់
បារាំង (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
ហ្សកហ្ស៊ី
អាល្លឺម៉ង់
ក្រិក
ហុងគ្រី
អ៊ីស្លង់
អៀរឡង់
អ៊ីតាលី
កាហ្សាក់ស្ថាន
កូសូវ៉ូ
កៀហ្ស៊ីគីស្ថាន
ឡេតូនី
លិចតិនស្តាញ
ហូឡង់ (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
អៀរឡង់ខាងជើង ***
ន័រវែស (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
ប៉ូឡូញ
ព័រទុយហ្គាល់ (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
រ៉ូម៉ានី
រុស្ស៊ី
សាំងម៉ារ៉ាំង
ហ្សែប
ស្លូវ៉ាគី
ស្លូវេនី
អេស្ប៉ាញ
ស៊ុយអែត
ស្វីស
តាហ្ស៊ីគីស្ថាន
តួគី
តួកមេនីស្ថាន
អ៊ុយក្រែន
អូសបេគីស្ថាន
បូរីវ៉ាទីកង់

**Macau S.A.R **ពិតជាមានសិទ្ធិគ្រប់គ្រាន់**ហើយត្រូវបានបញ្ចូលដូចខាងលើនេះ សម្រាប់តែគោលបំណងកម្មវិធីឆ្នោតនេះប៉ុណ្ណោះ។ បុគ្គលដែលកើតនៅតំបន់ Macau S.A.R ត្រូវទាញយកលក្ខណៈសមស្របរបស់ខ្លួនពីប្រទេសព័រទុយហ្គាល់។

*** សម្រាប់តែគោលបំណងកម្មវិធីឆ្នោត DV ប៉ុណ្ណោះ អៀរឡង់ខាងជើងត្រូវបានវាយតម្លៃដោយឡែក។ អៀរឡង់ខាងជើង**ពិតជាមានសិទ្ធិគ្រប់គ្រាន់**ហើយត្រូវបានបញ្ចូលទៅក្នុងចំណោមតំបន់ដែលមានសិទ្ធិគ្រប់គ្រាន់ផ្សេងទៀត។

****បុគ្គលដែលកើតនៅបណ្ដាប្រជុំកោះហាបូមី ស៊ីកូតាន គូណាស៊ីរី និងអេតូរ៉ូហ្វូនឹងយកទៅតាមប្រទេសជប៉ុន។ បុគ្គលដែលកើតនៅខេត្តសាខាលីនខាងត្បូងនឹងយកទៅតាមប្រទេសរុស្ស៊ី។

ប្រជាជនដើមនៃបណ្ដាប្រទេសខាងក្រោម**គ្មាន**សិទ្ធិចុះឈ្មោះនៅក្នុងកម្មវិធីឆ្នោត DV ឆ្នាំនេះឡើយ៖ ចក្រភពអង់គ្លេស (United Kingdom) ។ ចក្រភពអង់គ្លេស (United Kingdom) រួមមានតំបន់រណបដូចជា៖ Anguilla, Bermuda, British Virgin Islands, Cayman Islands, Falkland Islands, Gibraltar, Montserrat, Pitcairn, St. Helena, និង Turks and Caicos Islands។

## តំបន់អាមេរិកខាងជើង

The Bahamas

ក្នុងតំបន់អាមេរិកខាងជើង ប្រជាជនដើមរបស់កាណាដានិងម៉ិចស៊ិក**គ្មាន**សិទ្ធិចុះឈ្មោះនៅក្នុងកម្មវិធីឆ្នោត DV នៅឆ្នាំនេះឡើយ។

## តំបន់អូសេអានី

អូស្ត្រាលី (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
ហ្វីជី
គីរីបាទី
តំបន់កោះម៉ាហ្សាល
មីក្រូណេស៊ី រដ្ឋសហព័ន្ធណូរូ
ណូវែលសេឡង់ (រួមទាំងផ្នែកនិងតំបន់រណបនៅបរទេស)
ប៉ាលូ
ប៉ាពូនូវែលហ្គីណេ
សាម៉ូអា
តំបន់កោះសូលូម៉ង់
តុងហ្គា
ទូវ៉ាលូ
វ៉ានូទូ

## តំបន់អាមេរិកខាងត្បូង អាមេរិកកណ្ដាល និងតំបន់ការ៉ាអ៊ីប

អង់ទីហ្គានិងបាប៊ុយដា
អាហ្សង់ទីន
បាបាដុស
បេលី
បូលីវី
ហុងឌូរ៉ាស
នីការ៉ាហ្គា
ប៉ាណាម៉ា
ប៉ារ៉ាហ្គាយ
សាំងគិតស៍និងណេវីស

ស៊ីលី
កូស្តារីកា
គុយបា
ដូមីនីក
អេក្វាទ័រ
ហ្គ្រើណាដ
ក្វាតេម៉ាឡា
ហ្គីយ៉ាន
សាំងលូស៊ី
សាំងវិនសង់ត៍និងហ្គ្រើណាដង់
សូរីណាម
ទ្រីនីដាដនិងតូបាហ្គោ
អ៊ូរ៉ាហ្គាយ
វ៉េណេស៊ុយអេឡា

ប្រទេសនៅក្នុងតំបន់នេះមានប្រជាជនដើមដែល**គ្មាន**សិទ្ធិចុះឈ្មោះនៅក្នុងកម្មវិធីឆ្នោត DV នៅឆ្នាំនេះ៖

ប្រេស៊ីល កូឡុំប៊ី សាធារណរដ្ឋដូមីនីក អែលសាល់វ៉ាឌ័រ ហៃទី ហ្សាម៉ាអ៊ីក ម៉ិកស៊ិក និងប៉េរូ។